# អង្គការសហប្រជាជាតិ

**E**

---

សំរាប់ចែកចាយជាទូទៅ

**ក្រុមប្រឹក្សាសេដ្ឋកិច្ច**
**និង សង្គមកិច្ច**

E/CN.4/2005/116
ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៤
អត្ថបទដើម: ភាសាអង់គ្លេស

---

គណៈកម្មាធិការសិទ្ធិមនុស្ស
សម័យប្រជុំលើកទី ៦១
របៀបវារៈបណ្តោះអាសន្ន ចំណុចទី ១៩

## សេវាប្រឹក្សាយោបល់ និង សហប្រតិបត្តិការ ផ្នែកបច្ចេកទេស ក្នុងវិស័យសិទ្ធិមនុស្ស

ស្ថានការណ៍សិទ្ធិមនុស្សនៅប្រទេសកម្ពុជា

របាយការណ៍របស់លោក ភីធឺរ លយប្រ៉ែកត៍ តំណាងពិសេសរបស់លោកអគ្គលេខាធិការ
អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅប្រទេសកម្ពុជា

# សេចក្ដីសង្ខេប

លោកតំណាងពិសេសបានបំពេញបេសកកម្មលើកទី១១ របស់លោកមកកាន់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៤ ។ ក្នុងការបំពេញអាណត្តិរបស់លោក លោកតំណាងពិសេសបន្តវាយតំលៃលើសេរីភាព លោកបានពិភាក្សាដោយចំហរជាមួយតំណាងនានារបស់រដ្ឋាភិបាល ហើយលោកទទួលបានការគាំទ្រពីផ្នែកអង្គការក្រៅរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ ។

រដ្ឋាភិបាលថ្មី ដែលជារដ្ឋាភិបាលចំរុះរវាងគណៈបក្សប្រជាជនកម្ពុជា (CPP) និងគណៈបក្សរណៈសិរ្សរួបរួមជាតិដើម្បីកម្ពុជាឯករាជ្យ អព្យាក្រឹត្យ សន្តិភាព និងសហប្រតិបត្តិការ (FCP) ត្រូវបានបង្កើតឡើងកាលពីខែកក្កដា ឆ្នាំ ២០០៤ បន្ទាប់ពីមានភាពទាល់ច្រកខាងនយោបាយដែលបានអូសបន្លាយអស់រយៈពេលជិតមួយឆ្នាំមក ។ រដ្ឋាភិបាលថ្មីត្រូវបានបង្កើតឡើងបន្ទាប់ពីមានកិច្ចដំណើរអធម្មនុញ្ញភាពមួយ ហើយលោកតំណាងពិសេសមានសេចក្ដីព្រួយបារម្ភជាច្រើនអំពីអានាគតនៃរបបនយោបាយប្រជាធិបតេយ្យពហុបក្សនៅក្នុងប្រទេសកម្ពុជា ។

លោកតំណាងពិសេសមានសេចក្ដីព្រួយបារម្ភជាពិសេសអំពីការបន្តមានបញ្ហានីទណ្ឌភាព ដែលបញ្ហានេះបានក្លាយជាលក្ខណៈប្រព័ន្ធទៅហើយ។ ត្រូវតែលះបង់ចោល និងត្រូវតែបញ្ចប់ ។ បញ្ហានីទណ្ឌភាពបានបណ្ដោយឱ្យមានការគៀចវេសពីការទទួលខុសត្រូវ តាមរយៈសកម្មភាពបំរើផលប្រយោជន៍ដែលផ្ដល់ឱ្យ ហើយដែលបានបង្ក្រាប និងធ្វើឱ្យចុះខ្សោយដល់សំលេងចោទសួរអំពីគោលនយោបាយ និងការអនុវត្តបច្ចុប្បន្ន ។ បុគ្គល និងក្រុមមនុស្សដែលទទួលខុសត្រូវចំពោះការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ជាពិសេសសមាជិកយោធា នគរបាល កងរាជអាវុធហត្ថ និងកំលាំងប្រដាប់អាវុធដទៃទៀត មិនទាន់ត្រូវបានចាប់ខ្លួន និងចោទប្រកាន់តាមផ្លូវតុលាការនៅឡើយ ។ នេះបង្ហាញឱ្យឃើញច្បាស់ថា បញ្ហានីទណ្ឌភាពកើតមានមិនត្រឹមតែដោយសារសមត្ថភាពទាបនៅក្នុងស្ថាប័នអនុវត្តច្បាប់ និងស្ថាប័នតុលាការទន់ខ្សោយប៉ុណ្ណោះទេ ។ នីទណ្ឌភាពក៏បានធ្វើឱ្យអន្តរាយដល់ការជឿនលឿនក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចនៃប្រទេសកម្ពុជាសំរាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋភាគច្រើនរបស់ខ្លួន ។

ប្រទេសកម្ពុជាមិនទាន់បង្កើតឱ្យមានស្ថាប័នរដ្ឋអាញ្យាកិត្យនៅឡើយ ការត្រួតពិនិត្យលើអំណាចនីតិប្រតិបត្តិ និងមធ្យោបាយដើម្បីពង្រឹងការអនុវត្តសិទ្ធិដែលបានធានាដោយច្បាប់ និងរដ្ឋធម្មនុញ្ញ ។ តុលាការមិនអាចដំណើរការការងាររបស់ខ្លួនដោយឯករាជ្យ និងមិនលំអៀងបានទេ នៅពេលដែលប្រឈមមុខនឹងផលប្រយោជន៍របស់ជនទាំងឡាយដែលមានឥទ្ធិពល និងអំណាចនយោបាយ និងសេដ្ឋកិច្ច ។ អំណាចតុលាការនៅតែស្ថិតក្រោមការជ្រៀតជ្រែកពី

អំណាចនីតិប្រតិបត្តិ និងបើកឱ្យមានអំពើពុករលួយជាដដែល ហើយបញ្ហាសិទ្ធិមនុស្សកើតមានដោយគ្មានត្រួតពិនិត្យ ។ កិច្ចខិតខំប្រឹងប្រែងជាច្រើន ដើម្បីធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌នៅក្នុងអំឡុងពេលមួយទសវត្សកន្លងទៅនេះ មិនទទួលមានភាពរីកចំរើនជាដុំកំភួនក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ទេ ទោះបីជាស្ថាប័នពាក់ព័ន្ធក្នុងកិច្ចដំណើរការធ្វើផែនការ និងការបណ្តុះបណ្តាលក្នុងវិស័យយុត្តិធម៌បានបង្ហាញថាមានការរីកចំរើនខ្លះនៅក្នុងអំឡុងពេលមួយឆ្នាំកន្លងទៅនេះក៏ដោយ ។ វិស័យយុត្តិធម៌អាចរីកចំរើនទៅបាន លុះត្រាតែមានការគាំទ្រខាងនយោបាយ ពីថ្នាក់ខ្ពស់បំផុតនៃរដ្ឋាភិបាល ។

កាលពីខែតុលា ឆ្នាំ២០០៤ រដ្ឋសភា និងព្រឹទ្ធសភាបានអនុម័តច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតឱ្យមានអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ហើយបានធ្វើវិសោធនកម្មច្បាប់ឆ្នាំ២០០១ ស្តីពីការបង្កើតអង្គជំនុំជំរះវិសាមញ្ញ ។ បញ្ហាថវិកា និងមូលនិធិ បានរាំងដល់ការរីកចំរើននេះ ហើយត្រូវតែជំនះជាបន្ទាន់ ។ ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបត្រូវតែយល់ដឹងពីហេតុការណ៍ដែលបានកើតឡើង ហើយត្រូវស្វែងរកយុត្តិធម៌ក្នុងរឿងទាំងនេះ ។ សំខាន់ផងដែរគឺ ការបង្កើនអតិបរមានូវសត្តានុភាពសំរាប់ការកាត់សេចក្តីឱ្យមានលទ្ធផលវិជ្ជមានជាយថាហេតុរយៈពេលវែង សំរាប់ប្រព័ន្ធច្បាប់កម្ពុជា និងសំរាប់ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ។

លោកតំណាងពិសេសនៅតែមានសេចក្តីព្រួយបារម្ភអំពីការរិតត្បិតដល់សេរីភាពក្នុងការប្រជុំ និងការបង្កើតសមាគមដែលមានជារៀងរហូតមក ចាប់តាំងពីមានកុប្បកម្មប្រឆាំងនឹងថៃ កាលពីខែមករា ឆ្នាំ២០០៣ ។ នៅក្នុងរយៈកាលនេះ មានសំណើរជាង៣០ ស្នើសុំធ្វើការប្រមូលផ្តុំដោយសន្តិវិធី ហើយត្រូវបានសាលាក្រុងភ្នំពេញបដិសេធជារឿយៗ ការបដិសេធនេះធ្វើឡើងដោយខ្វះការពិចារណា ហើយជួនកាលមិនបានផ្តល់ហេតុផលទាល់តែសោះ ។ សន្ទស្សន៍ខ្លះក៏បានបង្ហាញថាមានការរិតត្បិតដល់សេរីភាពក្នុងការប្រជុំ ការបង្កើតសមាគម និងការដើរហើរនៅតំបន់ផ្សេងៗនៃប្រទេសកម្ពុជា ដែលនេះជាការរំលោភលើរដ្ឋធម្មនុញ្ញ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

នៅក្នុងអំឡុងបេសកកម្មលើទី១១ លោកតំណាងពិសេសបានចេញរបាយការណ៍មួយស្តីពីដីសម្បទាន គោលដៅសេដ្ឋកិច្ច ទស្សនៈវិស័យខាងសិទ្ធមនុស្ស ។ សិក្សាស្រាវជ្រាវសំរាប់ធ្វើរបាយការណ៍នេះបានបង្ហាញឱ្យឃើញច្បាស់ថាប្រព័ន្ធសម្បទានមិនបានទទួលជោគជ័យទេ ហើយត្រូវតែធ្វើការពិចារណាឡើងវិញ ។ ប្រព័ន្ធនេះបាននាំឱ្យមានការរំលោភសិទ្ធិមនុស្សនៃប្រជាពលរដ្ឋមូលដ្ឋាន ។ ទន្ទឹមគ្នានេះដែរប្រជាពលរដ្ឋកម្ពុជាទាំងមូលក៏មិនបានទទួលអត្ថប្រយោជន៍ពីប្រព័ន្ធនេះដែរ ព្រោះប្រព័ន្ធនេះមិនបានបង្កើនប្រាក់ចំណូលរដ្ឋជាដុំកំភួននោះទេ ។ លោកតំណាង

ពិសេសមានការជឿជាក់ចំពោះសន្ទរកថារបស់លោកនាយករដ្ឋមន្ត្រី ដែលបានថ្លែងបើកវេទិកាជាតិស្តីពីដីធ្លី កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ និងចំពោះការព្រមព្រៀងនៅក្នុងកិច្ចប្រជុំរវាងប្រទេសអ្នកផ្តល់ជំនួយ និងរដ្ឋាភិបាលកាលពីខែធ្នូកន្លងទៅនេះ ។ លោកបញ្ជាក់ពីសារៈសំខាន់ក្នុងការប្រកាសជាសាធារណៈនូវព័ត៌មានស្តីពីសម្បទានទាំងអស់ ។ ប្រព័ន្ធតំបន់អភិវឌ្ឍន៍យោធាក៏ត្រូវយកចិត្តទុកដាក់ជាពិសេសផងដែរ ។ កិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទនឹងជួបការលំបាក ប្រសិនបើគ្មានពត៌មានទាំងនេះទេ ។

លោកតំណាងពិសេសមានការជឿជាក់ចំពោះគំនិតផ្តួចផ្តើម ដែលធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាល និងសាលាក្រុងភ្នំពេញ ក្នុងការលើកកំពស់ការអភិវឌ្ឍន៍ទីក្រុងដោយវិធីដោះស្រាយផ្អែកលើមូលដ្ឋានគោលការណ៍សិទ្ធិមនុស្ស ។ ទោះជាយ៉ាងណាក្តី ការជម្លៀសប្រជាពលរដ្ឋដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងនៅកន្លែងផ្សេងទៀតនៅតែជាបញ្ហាដែលគួរឱ្យព្រួយបារម្ភដដែល ។

ការរីករាលដាលនៃអំពើពុករលួយ នៅតែជាឧបសគ្គកើតមានសំរាប់ការបង្កើតនីតិរដ្ឋ និងក្នុងការសំរេចការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ។ កាលពីខែកញ្ញា ឆ្នាំ២០០៤ លោកនាយករដ្ឋមន្ត្រីបានប្រកាស "សង្គ្រាមប្រឆាំងអំពើពុករលួយ " ដើម្បីឆ្លើយតបទៅនឹងការព្រមានពីសំណាក់ទីភ្នាក់ងារអភិវឌ្ឍន៍ និងទីភ្នាក់ងារហិរញ្ញវត្ថុអន្តរជាតិនានា ។ បញ្ហានេះគួរអនុវត្តនូវជំហានជាក់លាក់មួយចំនួន ឧទាហរណ៍ដូចជា ប្រទេសកម្ពុជាគួរចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ ហើយត្រូវអនុម័ត និងអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយឱ្យបានស្របតាមការទំលាប់អន្តរជាតិដ៏ប្រសើរបំផុត ដែលមាននៅក្នុងអនុសញ្ញានេះ ។

# មាតិការឿង


| | | កថាខណ្ឌ | ទំព័រ |
|---|---|---|---|
| | **សេចក្តីផ្តើម** | ១ | ៥ |
| I. | **បេសកកម្មលើកទី១១ របស់តំណាងពិសេសនៃលោកអគ្គលេខាធិការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ។** | ២-៣ | ៥ |
| II. | **ការវិវឌ្ឍន៍ចម្បងៗ និងបញ្ហាគួរឱ្យព្រួយបារម្ភមួយចំនួនទាក់ទងនឹងសិទ្ធិមនុស្ស** | ៤-៧៤ | ៧ |
| | ក. ការវិវត្តន៍ខាងនយោបាយ | ៤-៩ | ៧ |
| | ខ. ការរំលោភសិទ្ធិមនុស្សជាប្រព័ន្ធ និងនីទណ្ឌភាព | ១០-១៩ | ៩ |
| | គ. វិស័យយុត្តិធម៌ និងនីតិរដ្ឋ | ២០-៣៣ | ១៣ |
| | ឃ. ការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម | ៣៤-៣៦ | ១៨ |
| | ង. សេរីភាពជាមូលដ្ឋាន | ៣៧-៤១ | ១៩ |
| | ច. ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ | ៤២-៥៧ | ២១ |
| | ឆ. សិទ្ធិខាងលំនៅដ្ឋាន | ៥៨-៦០ | ២៦ |
| | ជ. អំពើពុករលួយ និងតម្លាភាព | ៦១-៦៨ | ២៧ |
| | ឈ. កាតព្វកិច្ចសន្ធិសញ្ញាអន្តរជាតិ | ៦៩-៧៤ | ២៩ |
| III. | **សេចក្តីសន្និដ្ឋាន** | ៧៥-៧៧ | ៣១ |
| IV. | **អនុសាសន៍** | ៧៨-១០៧ | ៣២ |
| | ក. ស្ថាប័នប្រជាធិបតេយ្យ | ៧៩-៨១ | ៣២ |
| | ខ. ការរំលោភសិទ្ធិមនុស្សជាប្រព័ន្ធ និងនីទណ្ឌភាព | ៨២-៨៦ | ៣២ |
| | គ. វិស័យយុត្តិធម៌ និងនីតិរដ្ឋ | ៨៧-៨៨ | ៣៣ |
| | ឃ. សេរីភាពជាមូលដ្ឋាន | ៨៩-៩២ | ៣៤ |
| | ង. ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ | ៩៣-១០០ | ៣៤ |
| | ច. សិទ្ធិខាងលំនៅដ្ឋាន | ១០១ | ៣៥ |
| | ឆ. អំពើពុករលួយ និងតម្លាភាព | ១០២-១០៤ | ៣៥ |
| | ឈ. កាតព្វកិច្ចសន្ធិសញ្ញាអន្តរជាតិ | ១០៥-១០៧ | ៣៦ |

# សេចក្តីផ្តើម

១.	របាយការណ៍នេះត្រូវបានដាក់ជូនស្របតាមសេចក្តីសំរេចចិត្តលេខ២០០៤/៧៩ នៃគណៈកម្មាធិការសិទ្ធិមនុស្ស ។ នេះគឺជារបាយការណ៍លើកទី៥ របស់លោកតំណាងពិសេសដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្ស ។ របាយការណ៍នេះគឺជាការសរសេរសេរបន្ថែមទៅលើរបាយការណ៍លើកមុនរបស់លោកតំណាងពិសេស ដែលបានដាក់ជូនគណៈកម្មាធិការសិទ្ធមនុស្ស និងមហាសន្និបាត ។ គោលបំណង និងវិធីសាស្ត្រស្ថិតនៅដូចបានរៀបរាប់នៅក្នុងរបាយ-ការណ៍មុនៗ ។

## I- បេសកកម្មលើកទី១១ របស់តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

២.	នៅក្នុងអំឡុងពេលទស្សនកិច្ចលើកទី១១ របស់លោកមកកាន់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៤ លោកតំណាងពិសេសបានផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ បញ្ហានិទណ្ឌភាព និងអំពើពុករលួយនៅតែមាន ។ លោកបានពិភាក្សាអំពីបរិយាកាសទូទៅខាងនយោបាយបន្ទាប់ពីការបង្កើតរដ្ឋាភិបាលថ្មី កាលពីខែកក្កដា ឆ្នាំ២០០៤ និងបានពិនិត្យលើបញ្ហានានាស្តីពីកំណែទម្រង់វិស័យយុត្តិធម៌ សេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពក្នុងការប្រជុំ សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច និងបញ្ហានានាទាក់ទងនឹងការកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ លោកបានគូសបញ្ជាក់ជាថ្មីនូវអនុសាសន៍របស់លោកចំពោះការបង្កើតគណៈកម្មាធិការឯករាជ្យមួយ ដើម្បីស៊ើបអង្កេតនូវបាតុភាពនៃការសំលាប់ដោយហ្វូងមនុស្ស ។ លោកតំណាងពិសេសបានចេញរបាយការណ៍មួយស្តីពីដីសម្បទានគោលដៅសេដ្ឋកិច្ច ផ្អែកលើទស្សនវិស័យខាងសិទ្ធិមនុស្សនៅចុងបេសកកម្មរបស់លោក ហើយលោកបានអំពាវនាវសុំឱ្យប្រកាសជាសាធារណៈអំពីសម្បទានទាំងអស់នៅក្នុងប្រទេសកម្ពុជា ។

៣.	លោកតំណាងពិសេសបានអនុញ្ញាតចូលជួបសវនាការជាមួយព្រះមហាក្សត្រនរោត្តមសីហមុនី ។ លោកបានជួបពិភាក្សាជាមួយលោកនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រី ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ គណៈបក្សនយោបាយប្រឆាំង តុលាការ និងនគរបាល ។ លោកក៏បានជួបប្រជុំជាមួយតំណាងសហជីពកម្មករ ជនជាតិដើមភាគតិច សមាគមមេធាវី អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិលប្រព័ន្ធសារពត៌មាន បេសកកម្មការទូត ក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា ទីភ្នាក់ងារអភិវឌ្ឍន៍ និងប្រទេសអ្នកផ្តល់ជំនួយទ្វេរភាគី និងពហុភាគី ។ លោកក៏បានជួបជាមួយ ប្រជាពលរដ្ឋដែលបានរាយការណ៍អំពីការរំលោភសិទ្ធិ

មនុស្សរបស់ខ្លួន ។ ដោយមានការអមដំណើរពីតំណាងសាលាក្រុងភ្នំពេញ លោកបានទៅធ្វើទស្សនកិច្ចអតីតរោងកុនហែមជាតិស្ថិតនៅកណ្តាលរាជធានីភ្នំពេញ ដែលនៅទីនោះមានប្រជាពលច្រើនជាង១០០ គ្រួសាររស់នៅក្នុងស្ថានភាពអមនុស្សធម៌ និងដែលមិនអាចទទួលយកបាន ។

## II. ការវិវត្តន៍ចម្បងៗ និងបញ្ហាគួរឱ្យព្រួយបារម្ភមួយចំនួនទាក់ទងនឹងសិទ្ធិមនុស្ស

### ក- ការវិវត្តន៍ខាងនយោបាយ

៤. រដ្ឋាភិបាលថ្មីត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ដែលមានសមាសភាពគណៈបក្សប្រជាជន (CPP) និងគណៈបក្សរណសិរ្សរួបរួមជាតិ ដើម្បីកម្ពុជាឯករាជ្យ អព្យាក្រឹត្យ សន្តិភាព និងសហប្រតិបត្តិការ (FUNCINPEC) ។ រដ្ឋាភិបាលត្រូវបានបង្កើតឡើងបន្ទាប់ពីការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដោយតំណាងរាស្ត្រទាំងអស់ដែលបានជាប់ឆ្នោត ហើយដែលមិនទាន់ចូលកាន់តំណែង ដែលតម្រូវឱ្យតំណាងរាស្ត្រទាំងអស់ ធ្វើការបោះឆ្នោតអនុម័តយល់ព្រមលើតំណែងរបស់រដ្ឋាភិបាល និងថ្នាក់ដឹកនាំរដ្ឋសភាថ្មីនៅពេលជាមួយគ្នា ដោយការលើកដៃជំនួសឱ្យការបោះឆ្នោតដាច់ដោយឡែកពីគ្នា និងតាមរយៈសន្លឹកបោះឆ្នោតសំងាត់ ដូចដែលបានតម្រូវនៅពេលកន្លងមក ។

៥. រដ្ឋាភិបាលថ្មីមានសមាជិកប្រមាណជា២ ដង នៃសមាជិករដ្ឋាភិបាលចាស់ ហើយក្នុងនោះរួមមានតំណែងសំរាប់ឧបនាយករដ្ឋមន្ត្រីចំនួន៧ រូប ទេសរដ្ឋមន្ត្រីចំនួន១៥ រូប រដ្ឋមន្ត្រីចំនួន២៨ រូប និងរដ្ឋលេខាធិការចំនួន១៣៥ រូប ។ ចំនួននេះបានធ្វើឱ្យប្រទេសកម្ពុជាមានខុទ្ទកាល័យធំជាងគេបំផុតនៅលើពិភពលោក ។ ក្រៅពីនេះមានអនុរដ្ឋលេខាធិការចំនួន១៤៦ រូបត្រូវបានតែងតាំង ។ មានការព្រមព្រៀងគ្នាថានឹងតែងតាំងអភិបាលខេត្ត ក្រុង និងស្រុកនៅទូទាំងប្រទេស បន្ថែមទៀតពីគណៈបក្សប្រជាជន និងគណៈបក្សហ្វ៊ុនស៊ីនប៉ិច សំរាប់ខេត្ត ក្រុង និងស្រុកទាំងអស់ ។

៦. កាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៤ ព្រះមហាក្សត្រព្រះបាទនរោត្តមសីហនុ បានដាក់រាជ្យ ។ បន្ទាប់ពីរដ្ឋសភាថ្មីបានអនុម័តច្បាប់ស្តីពីក្រុមប្រឹក្សារាជបល្ល័ង្កមក ព្រះអង្គម្ចាស់នរោត្តមសីហមុនី ព្រះរាជបុត្ររបស់ព្រះមហាក្សត្រព្រះបាទនរោត្តមសីហនុត្រូវបានជ្រើសតាំងជាព្រះមហាក្សត្រ នៅថ្ងៃទី១៤ ខែតុលា ។ ពិធីគ្រងរាជ្យត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី ២៩ ខែតុលា ។

៧. ក្រៅពីនេះ គឺត្រូវចំណាយរយៈពេលជិតមួយឆ្នាំដើម្បីបង្កើតរដ្ឋាភិបាលថ្មី បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រកាលពីខែ កក្កដា ឆ្នាំ២០០៣ ហើយការបង្កើតរដ្ឋាភិបាលថ្មីនេះ ត្រូវបានធ្វើឡើងតាមរយៈកិច្ចដំណើរការមួយដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ ។ នៅក្នុងពេលធ្វើរបាយការណ៍នេះ មានហេតុផលជាច្រើនទៀត ដែលត្រូវព្រួយបារម្ភអំពីអានាគតនៃរបបនយោបាយប្រជាធិបតេយ្យពហុបក្សនៅក្នុងប្រទេសកម្ពុជា ។ គណៈបក្សកាន់អំណាចទាំងពីរបានឈានដល់ការព្រមព្រៀងគ្នាមួយ ដែលមិនអើពើចំពោះសេចក្តីតម្រូវរបស់រដ្ឋធម្មនុញ្ញ ដើម្បីរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានៅក្នុងឆ្នាំ២០០៥ នេះ ហើយបែរជាសំរេចថានឹងធ្វើការតែងតាំងសមាជិកព្រឹទ្ធសភាដោយផ្ទាល់ទៅវិញ ។ ប្រធានភូមិមិនត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដូចបានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់ ឆ្នាំ២០០១ នោះទេ ។ ផ្ទុយទៅវិញ រូបមន្តមួយកំពុងស្ថិតក្នុងការពិភាក្សា ដែលគេបានកំណត់យកចំនួន៧0 ភាគរយនៃមេឃុំ ចៅសង្កាត់ ត្រូវជ្រើសតាំងពីគណៈបក្សប្រជាជនកម្ពុជា (CPP) ហើយ៣0 ភាគរយទៀតពីគណៈបក្សហ៊្វុនស៊ិនប៉ិច (FCP) ។ មានគណៈបក្សប្រឆាំងតែមួយគត់ គឺគណៈបក្សសមរង្ស៊ី នៅមិនទាន់ទទួលបានអាសនៈនៅក្នុងគណៈកម្មការនានារបស់រដ្ឋសភានៅឡើយទេ អាស្រ័យហេតុនេះ ត្រូវបានគេផាត់ចេញពីការត្រួតពិនិត្យសេចក្តីព្រាងច្បាប់សំខាន់ៗ នៅក្នុងគណៈកម្មការទាំងនេះ ។ មានសេចក្តីស្នើជាច្រើនពីតុលាការ និងក្រសួងយុត្តិធម៌សុំឱ្យដកអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភាពីគណៈបក្សប្រឆាំងចំនួន៣ រូប ដែលបច្ចុប្បន្ននេះកំពុងរងចាំរដ្ឋសភាបោះឆ្នោតអនុម័ត ។ កាលពីថ្ងៃទី១៨ ខែកក្កដា គឺមានរយៈពេល៣ ថ្ងៃបន្ទាប់រដ្ឋាភិបាលថ្មីត្រូវបានបង្កើត លោកនាយករដ្ឋមន្ត្រីបានធ្វើការចោទប្រកាន់គណៈបក្សសមរង្ស៊ីថាបានរៀបចំបង្កើតកំលាំងប្រដាប់អាវុធជាសំងាត់ ។ ចាប់ពីពេលនោះមក ការិយាល័យស៊ើបការណ៍យោធា និងមន្ត្រីអនុវត្តច្បាប់នានា បានរៀបចំចងក្រងបញ្ជីឈ្មោះជនទាំងឡាយដែលគេចោទថាជាសមាជិកនៃកំលាំងនេះ ។ នៅក្នុងពេលធ្វើរបាយការណ៍នេះ តុលាការយោធាបានចេញដីកាចោទប្រកាន់សមាជិកគណៈបក្សម្នាក់ ។ អ្នកដទៃទៀតត្រូវបានតុលាការកោះអញ្ជើញមកធ្វើការសាកសួរ ហើយអ្នកខ្លះទៀតបានលាក់ខ្លួន ។ មានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះជឿការចោទប្រកាន់នេះ ហើយមានមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលមកពីគណៈបក្សប្រជាជនបានប្រកាសជាសាធារណៈថា អាជ្ញាធរមិនមានភស្តុតាងអំពីការបង្កើតកំលាំងប្រដាប់អាវុធនោះទេ ។

៨. លទ្ធផលដ៏សំខាន់មួយនៃការវិវត្តន៍ផ្នែកនយោបាយនៅក្នុងអំឡុងពេលប៉ុន្មានខែកន្លងមកនេះ ហាក់មានការរីកលូតលាស់នៃការប្រមូលផ្តុំអំណាចនៅក្នុងដៃរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយបង្កើននូវទម្រង់រដ្ឋាភិបាលមួយដែលមានរូបភាពជាអត្តធិបតេយ្យ ។

៩. តាមសេចក្តីរាយការណ៍ដែលបានចេញដោយទីភ្នាក់ងារហិរញ្ញវត្ថុ និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនានា នៅឆ្នាំកន្លងទៅនេះបានបង្ហាញថា ជំនួយអភិវឌ្ឍន៍អន្តរជាតិដល់ប្រទេសកម្ពុជា មិនបាននាំមកនូវភាពរីកចំរើនដូចដែលបានរំពឹងទុកនោះទេ ហើយសំដែងនូវសេចក្តីព្រួយបារម្ភអំពីស្ថានការណ៍នៅថ្ងៃអានាគត ប្រសិនជាមិនធ្វើកំណែ

ទម្រង់ជាដំកំភួនទេនោះ ។ ទោះបីជាមានការរីកចំរើនខាងសេដ្ឋកិច្ចគួរឱ្យកត់សំគាល់ក្នុងរយៈពេលមួយទសវត្សនេះ គឺ ៦,៧ ភាគរយក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ១៩៩៤ និងឆ្នាំ២០០២ និងមានជំនួយយ៉ាងច្រើនឥតគណៈនាក្តី ក៏មិនឃើញមានការរីកចំរើនជាដំកំភួន ក្នុងការកាត់បន្ថយភាពក្រី ។ បើតាមរបាយការណ៍របស់អង្គការមូលនីធិរូបិយវត្ថុអន្តរជាតិ អាត្រាកំនើនអាចធ្លាក់ចុះក្រោម២ ភាគរយនៅក្នុងឆ្នាំ២០០៥ ហើយការធ្លាក់ចុះនេះនឹងឡើងវិញបន្តិចម្តង១បាន លុះត្រាតែប្រទេសកម្ពុជាជំរុញការធ្វើកំណែទម្រង់ឱ្យឿនឿនទៅមុខ ។ ការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចភាគច្រើនកើតមាននៅទីក្រុង ទន្ទឹមគ្នានេះការរីកលូតលាស់នៅតំបន់ជនបទ គឺមានល្បឿនយឺតបំផុត ដោយមានកំនើនប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋភាគច្រើនស្ថិតនៅក្នុងបន្ទាត់នៃភាពក្រីក្រ ។ តាមការប៉ាន់ស្មានរវាងពី៤០ និង៤៥ ភាគរយនៃប្រជាពលរដ្ឋទាំងអស់រស់នៅក្រោមបន្ទាត់នេះ ។ ការប្រើប្រាស់មុខទំនិញគ្រប់ប្រភេទសំរាប់មនុស្សម្នាក់គិតជាមធ្យមភាគបានធ្លាក់ចុះនៅចន្លោះឆ្នាំ១៩៩៣/៩៤ និង១៩៩៩ គឺពី២.២៦០ ទៅ ១.៨០០ រៀលក្នុងមួយថ្ងៃ ។ បើតាមរបាយការណ៍បានឱ្យដឹងថា ចំនួនគ្រឹះស្ថានឱសថសាធារណៈនៅថ្នាក់ឃុំ សង្កាត់ បានធ្លាក់ចុះនៅឆ្នាំ ២០០០ ដល់៦៨ ភាគរយធៀបនឹងឆ្នាំ១៩៨៩ ។ យោលដោយកង្វះអាហាររូបបថម កុមារចំនួន៤៥ ភាគរយបានក្លាយជាមនុស្សក្រិនក៏រិតមធ្យម ហើយ២១ ភាគរយទៀតបានក្លាយជាមនុស្សក្រិនក៏រិតធ្ងន់ធ្ងរ ។ អាត្រាមរណៈរបស់កុមារមានក៏រិតខ្ពស់បំផុតនៅតំបន់បូព៌ា និងអាស៊ីភាគអាគ្នេរ ហើយបច្ចុប្បន្ននេះអាត្រានេះឡើងខ្ពស់ជាងកាលពីមួយទសវត្សកន្លងទៅទៀត ។ មានប្រជាពលរដ្ឋពេញវ័យចំនួន៣៧ ភាគរយតែប៉ុណ្ណោះ ដែលជាអ្នកចេះអក្សរ ។

## ខ. ការរំលោភសិទ្ធិមនុស្ស និងនិទណ្ឌភាពដែលមានលក្ខណៈជាប្រព័ន្ធ

១០. លោកតំណាងពិសេសចាត់ទុកនិទណ្ឌភាព ជាបញ្ហាធ្ងន់ធ្ងរបំផុតនៅក្នុងប្រទេសកម្ពុជា ។ វាជាឧបសគ្គធំបំផុតសំរាប់ការខិតខំប្រឹងប្រែងការពារ និងធានាការគោរពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា និងក្នុងការបង្កើតលក្ខខណ្ឌផ្សេង១ សំរាប់ការប្រើប្រាស់សិទ្ធិទាំងនេះឱ្យបានពេញលេញ ។ នៅក្នុងអំឡុងពេលជាងមួយទសវត្សកន្លងទៅនេះ រដ្ឋាភិបាលត្រូវបានស្នើយ៉ាងទទូចជាច្រើនលើកសុំឱ្យចាត់វិធានការជាបន្ទាន់ និងមានប្រសិទ្ធភាព ដើម្បីដោះស្រាយបញ្ហានេះ ដោយមហាសន្និបាត និងគណៈកម្មាធិការសិទ្ធិមនុស្ស តំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ស្ថាប័នជំនាញនានាដែលទទួលខុសត្រូវត្រួតពិនិត្យការអនុវត្តរបស់កម្ពុជា ចំពោះសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និងដោយស្ថាប័ន និងអង្គការដទៃទៀត ។ ទោះជាយ៉ាងណាក៏ដោយ គេឃើញមានការរីកចំរើនតិចតួច ឬមិនមានទាល់តែសោះ ។

១១. តាមច្បាប់អន្តរជាតិ ប្រទេសកម្ពុជាត្រូវតែធ្វើការស៊ើបអង្កេតទាំងស្រុងរាល់ការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ហើយត្រូវចោទប្រកាន់ និងផ្តន្ទាទោសជនដែលទទួលខុសត្រូវ ប្រសិនបើរកឃើញថាជននោះមានពិរុទ្ធភាព ។ នេះ

មានន័យថាជនរងគ្រោះមានតួនាទីមួយ ក្នុងការការពារសិទ្ធិរបស់ខ្លួន និងទទួលបានការដោះស្រាយដោយត្រឹមត្រូវ យុត្តិធម៌ និងមានប្រសិទ្ធិភាព ដើម្បីធានាថាជនដែលទទួលខុសត្រូវ ត្រូវបានកាត់សេចក្តីដោយតុលាការ ហើយជនរងគ្រោះទទួលបានការជួសជុលសំណងជម្ងឺចិត្ត ។

១២. នៅក្នុងអំឡុងបេសកកម្មរបស់លោក លោកតំណាងពិសេសបានលើកយកកង្វល់របស់លោកអំពីបញ្ហានីទណ្ឌភាពមកពិភាក្សាជាមួយលោកនាយករដ្ឋមន្ត្រី និងជាមួយមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាល ហើយលោកបានសាកសួរអំពីស្ថានភាពនៃករណីរឿងចំនួន១៧៨ នៃការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ដែលបានលើកឡើងដោយលោកអតីតតំណាងពិសេសទាំងឡាយ និងការិយាល័យឧត្តមស្នងការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៤ ហើយដែលបានផ្ញើជូនរដ្ឋមន្ត្រីដែលពាក់ព័ន្ធនៃរដ្ឋាភិបាល កាលពីខែ កម្ភៈ ឆ្នាំ២០០៤ ។ លោកបានទទួលការឆ្លើយតប ហើយដែលនៅក្នុងពេលធ្វើរបាយការណ៍នេះ កំពុងធ្វើការវាយតំលៃ ។

១៣. ករណីទាំងនេះបង្ហាញពីលំនាំមួយដែលស៊ីសង្វាក់ និងនៅតែបន្តមាននៃបញ្ហានីទណ្ឌភាព ដែលក្នុងនោះមានករណីលោក ហូ សុខ រដ្ឋលេខាធិការ ត្រូវបានគេធ្វើឃាដនៅក្នុងបរិវេណក្រសួងមហាផ្ទៃ នៅរាជធានីភ្នំពេញកាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៧ និងមរណៈភាពរបស់បុរសវ័យក្មេងម្នាក់ឈ្មោះប្រាក់ ស៊ីថា នៅក្នុងក្រសួងដដែលនេះ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៣ បន្ទាប់ពីបានធ្វើការវាយដំដោយមន្ត្រីនគរបាលមួយរូបដែលគេស្គាល់ឈ្មោះ ។ មិនមាននរណាម្នាក់ត្រូវគេចាប់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះទេ ។ គ្មាននរណាម្នាក់ត្រូវបានផ្តន្ទាទោសចំពោះការធ្វើឃាដអ្នកកាសែតចំនួន៨ រូប និងការវាយប្រហារយ៉ាងឃោរឃៅទៅលើតំណាងប្រព័ន្ធសារពត៌មាន ដែលកើតមាននៅក្នុងទសវត្សរកន្លងទៅនេះ ឬចំពោះឃាដកម្មទៅលើប្រធានសហជីពកម្មករពីររូប និងការវាយប្រហារទៅលើសកម្មជនសហជីពកម្មករនៅក្នុងអំឡុងឆ្នាំ២០០៤ ។ ចាប់តាំងពីឆ្នាំ២០០០ មក ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ចងក្រងករណីឃាដកម្មលើមនុស្សចំនួន៤៣ នាក់ ក្នុងការវាយប្រហារទៅលើសកម្មជននយោបាយដែលល្បីឈ្មោះ ដែលគេសង្ស័យថាជាមូលហេតុនយោបាយ ។ ករណីភាគច្រើននៃករណីទាំងនេះ មិនមានជនណាម្នាក់ត្រូវបានផ្តន្ទាទោស និងដាក់ពន្ធនាគារឡើយ ។ នៅក្នុងករណីជាច្រើនដែលជនសង្ស័យត្រូវបាននាំខ្លួនទៅសវនាការ មានការព្រួយបារម្ភអំពីការស៊ើបអង្កេត និងការចោទប្រកាន់តាមផ្លូវតុលាការ ការមិនអនុវត្តបទដ្ឋានអប្បបរមាស្តីពីការជំនុំជំរះប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ និងបញ្ហាស្តីពីពិរុទ្ធភាពពិតប្រាកដរបស់ពិរុទ្ធជន ។ នៅក្នុងករណីផ្សេងទៀត ឧទាហរណ៍តុលាការសំរេចព្យួរទោស ឬកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលខ្លី ភាពគ្រប់គ្រាន់នៃការផ្តន្ទាទោសគឺជាបញ្ហាមួយដែរ ។ នៅក្នុងរយៈពេលមួយទសវត្សរកន្លងទៅនេះ ឃើញមានករណីជាច្រើនទាក់ទងនឹងការឃាយី និងអំពើហឹង្សាទៅលើអ្នកការពារសិទ្ធិមនុស្ស ដែលរៀបចំចងក្រងឯកសារ និងធ្វើរបាយ-ការណ៍អំពីការរំលោភសិទ្ធិមនុស្ស ។

១៤. នេះបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា បញ្ហានីទណ្ឌភាពបណ្តាលមកពីសមត្ថភាពទាបនៅក្នុងស្ថាប័នអនុវត្តច្បាប់ និងតុលាការទន់ខ្សោយ ។ ដោយការលើកស្ទួយប្រព័ន្ធមួយ ដែលក្នុងនោះមានស្ថាប័ន និងបុគ្គល ដែលបានជ្រើសរើសឡើងត្រូវគេបណ្តោយឱ្យធ្វើបំពានច្បាប់ និងរំលោភសិទ្ធិមនុស្សដោយមិនបានចាប់នរណាម្នាក់ឱ្យទទួលខុសត្រូវចំពោះទង្វើនោះ ជនដែលមានអំណាចខាងសេដ្ឋកិច្ច និងនយោបាយ អាចមានលទ្ធភាពរកមានបានផ្ទាល់ខ្លួន និងផលប្រយោជន៍ដែលផ្តល់ឱ្យ ។ បញ្ហានីទណ្ឌភាពបានបណ្តោយឱ្យជនល្មើសគេចវេសពីការទទួលខុសត្រូវតាមរយៈសកម្មភាពគាបសង្កត់ និងធ្វើឱ្យចុះខ្សោយដល់សំលេងដែលចោទសួរអំពើគោលនយោបាយ និងទំលាប់អនុវត្តដែលមាន ទោះជាអ្នកទាំងនោះជាសកម្មជននយោបាយ សមាជិកសហជីពកម្មករ អ្នកកាសែត ឬប្រជាពលរដ្ឋដែលគាំទ្រសិទ្ធិមនុស្សក៏ដោយ ។

១៥. ការវិភាគរបស់លោកតំណាងពិសេសចំពោះលំនាំ និងករណីមួយចំនួនស្តីពីការរំលោភសិទ្ធិមនុស្សនៅទសវត្សកន្លងទៅនេះ បង្ហាញថាការរំលោភសិទ្ធិមនុស្ស ជារឿយៗមិនបានធ្វើឡើងដោយការបញ្ជាផ្ទាល់ពីអ្នកកាន់អំណាចសំខាន់ៗនោះទេ ប៉ុន្តែវាជាការបណ្តោយឱ្យធ្វើដោយសារក្នុងនោះមានជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍ដែលផ្តល់ឱ្យ ។ ដូច្នេះហើយសមាជិកនៃកំលាំងប្រដាប់អាវុធ នគរបាល និងមន្ត្រីឯទៀត ជាធម្មតាមិនត្រូវបានចាប់ខ្លួន និងធ្វើការផ្តន្ទាទោសតាមផ្លូវច្បាប់ទេ សូម្បីតែមានការសង្ស័យ និងមានភស្តុតាងដែលអាដ្ឋាធរ និងសាធារណៈជនទូទៅបានដឹងយ៉ាងច្បាស់ហើយក៏ដោយ ។

១៦. មានករណីជាច្រើនដែលស្ថាប័នរដ្ឋបានអនុវត្តផ្ទុយទៅនឹងផលប្រយោជន៍ដែលផ្តល់ឱ្យ តំណាងស្ថាប័នទាំងនោះត្រូវស្ថិតក្រោមការគំរាមកំហែង និងការបំភិតបំភ័យ ។ នៅក្នុងទសវត្សកន្លងទៅនេះ លោកតំណាងពិសេសទាំងអស់បានលើឡើងជាសាធារណៈអំពីសេចក្តីព្រួយបារម្ភចំពោះការវាយប្រហារចំនួន១៨ លើកទៅលើសមាជិកតុលាការ ។ ការចូលពាក់ព័ន្ធពីសំណាក់យោធា និងនគរបាលត្រូវបានគេកត់ត្រានៅក្នុងករណីនេះភាគច្រើន ។ នៅពេលថ្មីៗនេះ កើតមានឧប្បត្តិហេតុមួយ កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៤ មានការគុបគ្រាប់បែកចូលក្នុងផ្ទះរបស់ព្រះរាជអាជ្ញាម្នាក់ដែលបំរើការនៅតុលាការខេត្តក្រចេះ ។ ករណីនេះចាំបាច់ត្រូវធ្វើការស៊ើបអង្កេតទាំងស្រុង ទោះបីជាមិនមានជនណាម្នាក់ត្រូវរងរបួសក៏ដោយ ។

១៧. ការកើតមានជាប្រចាំនូវការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបនៅក្នុងមន្ទីឃុំឃាំងនៅក្នុងទសវត្សកន្លងទៅនេះត្រូវបានរៀបចំចងក្រងជាឯកសារ ប៉ុន្តែបើតាមលោកតំណាងពិសេសដឹង គឺមានតែបុគ្គលម្នាក់គត់ដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារដោយការប្រព្រឹត្តសកម្មភាព

ល្មើសខាងលើនេះនៅក្នុងឆ្នាំ១៩៩៣ ។ វាមិនប្រាកដថា ជំនួយផ្នែកបច្ចេកទេស និងការខិតខំប្រឹងប្រែងកសាងសមត្ថភាព ដែលមានទិសដៅពង្រឹងស្ថាប័នអនុវត្តច្បាប់ និងស្ថាប័នតុលាការ នឹងសំរេចលទ្ធផលតាមការរំពឹងទុករបស់ប្រទេស អ្នកផ្តល់ជំនួយនោះទេ លុះត្រាតែលំនាំនៃបញ្ហានីទណ្ឌភាពត្រូវបានបញ្ចប់ ហើយរាល់សេចក្តីសំរេចនានាផ្នែកនយោបាយធ្វើឡើងដើម្បីដោះស្រាយបញ្ហានេះ ។ សភាពការណ៍បច្ចុប្បន្នដែលមន្ត្រីរដ្ឋាភិបាល និងបុគ្គលដែលមានអំណាចមានសេរីភាពប្រព្រឹត្តបំពានច្បាប់ ដោយមិនមានការចាប់ឱ្យទទួលខុសត្រូវបែបនេះ បានធ្វើឱ្យសាធារណៈជនទូទៅបាត់បង់ជំនឿទុកចិត្តយ៉ាងខ្លាំងទៅលើស្ថាប័នអនុវត្តច្បាប់ និងស្ថាប័នតុលាការ ។

១៨. សន្ទស្សន៍មួយទៀតនៃបញ្ហានេះ គឺបញ្ហាអំពើហឹង្សាដោយហ្វូងមនុស្សនៅតែបន្តមាន ។ ការិយាល័យឧត្តមស្នងការអង្គការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានរៀបចំចងក្រងឯកសារពាកព័ន្ធនឹងការសំលាប់មនុស្សចំនួន ២៦ នាក់ ដោយហ្វូងមនុស្សនៅក្នុងឆ្នាំ២០០៤ ។ នៅក្នុងអំឡុងបេសកកម្មរបស់លោក លោកតំណាងពិសេសបានទទួលព័តិមានពីលោកអគ្គនាយកនគរបាលជាតិថា នគរបាលបានចងក្រងឯកសារពាក់ព័ន្ធការសំលាប់ដោយហ្វូងមនុស្សចំនួន ៣០ ករណីនៅក្នុងឆ្នាំនេះ ។ បើតាមដែលលោកតំណាងពិសេដឹងមិនមានជន ណាម្នាក់ត្រូវបានធ្វើការចោទប្រកាន់តាមផ្លូវតុលាការទាក់ទងនឹងករណីនៃការសំលាប់ទាំងនេះ ។ នៅក្នុងអំឡុងពេលប្រាំឆ្នាំកន្លងទៅនេះ មានមនុស្សប្រមាណជាង១០០ នាក់បានបាត់បង់ជីវិតដោយអំពើហឹង្សានេះ ហើយមានមនុស្សជាច្រើននាក់ទៀតត្រូវរងរបួសធ្ងន់ ។ នៅក្នុងករណីផ្សេងទៀត មន្ត្រីអនុវត្តច្បាប់មួយចំនួនបានធ្វើការញុះញង់ហ្វូងមនុស្សឱ្យធ្វើការវាយប្រហារទៅលើជនសង្ស័យក្នុងអំពើចោរកម្ម ឬអំពើប្លន់ ។ ចាប់តាំងពីឆ្នាំ២០០២ លោកតំណាងពិសេសបានដាក់ចេញជាអនុសាសន៍ជាច្រើនលើកច្រើនសារសុំឱ្យបង្កើតក្រុមប្រឹក្សាសាកសួរឯករាជ្យមួយ ដែលមានសមាសភាពគណៈបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងអង្គការខាងសាសនានានាដែលបានបង្កើតឡើងដើម្បីពិនិត្យលើបញ្ហានេះ និងដើម្បីធ្វើការសាកសួរនគរបាល និងធ្វើការស៊ើបអង្កេត ។ លោកតំណាងពិសេសសង្ឃឹមថាអនុសាសន៍នេះនិងត្រូវបានរដ្ឋាភិបាលថ្មីពិនិត្យពិចារណា ។

១៩. លោកតំណាងពិសេសយល់ឃើញថា នីទណ្ឌភាពមានលក្ខណៈជាប្រព័ន្ធ នាំឱ្យមានការលៃបែងចែកធនធានសេដ្ឋកិច្ចបំភ្លើសតួលេខ ធ្វើឱ្យកើតមានភាពក្រីក្រតថែមទៀត ។ បញ្ហានេះបានធ្វើឱ្យខូចដល់ការធ្វើនិទស្សខាងច្បាប់ និងការជឿទុកចិត្តលើនីតិរដ្ឋដែលជាសេចក្តីត្រូវការចាំបាច់សំរាប់អ្នកវិនិយោគទុន បានកាត់បន្ថយនូវប្រាក់ចំណូលរដ្ឋដែលចាំបាច់សំរាប់ចំណាយលើសេវាសាធារណៈ ហើយបានធ្វើឱ្យបាត់បង់ជំនឿទុកចិត្តមកលើប្រទេសកម្ពុជា និងការប្រកួតប្រជែងនៅលើទីផ្សារពិភពលោក ។ បើចង់ឱ្យមានការរីកចំរើនក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចជាដំកំភួន និងប្រកបដោយចិរភាព ហើយបើចង់ឱ្យកិច្ចខិតខំប្រឹងប្រែង ដើម្បីបញ្ចប់ និងកាត់បន្ថយភាពក្រីក្របានសំរេចជោគជ័យនោះ គប្បីត្រូវជៀសវាង និងបញ្ចប់បញ្ហានីទណ្ឌភាព និងអំពើពុករលួយឱ្យបាន ។

## គ. វិស័យយុត្តិធម និងនីតិរដ្ឋ

២០. នៅក្នុងឆ្នាំកន្លងមកទៅនេះ ទីភ្នាក់ងារនៃប្រទេសអ្នកផ្តល់ជំនួយ និងទីភ្នាក់អភិវឌ្ឍន៍នានាបានយល់កាន់តែច្បាស់ថា នៅមិនទាន់មានយន្តការសំរាប់ធានាឱ្យមានការទទួលខុសត្រូវ ហើយនីតិរដ្ឋមិនទាន់មានភាពច្បាស់លាស់នៅឡើយ ។ ប្រទេសកម្ពុជាត្រូវតែបង្កើតឱ្យមានស្ថាប័នវដ្តឯករាជ្យ ការត្រួតពិនិត្យលើអំណាចនីតិប្រតិបត្តិ និងមធ្យោបាយនានាដើម្បីពង្រឹងការអនុវត្តសិទ្ធិដែលការពារដោយច្បាប់ និងរដ្ឋធម្មនុញ្ញ ។ ការខកខាននេះមិនមែនកើតមានដោយចៃដន្យ ឬដោយការធ្វេសប្រហែស ឬអសមត្ថភាពនោះទេ ។ តុលាការបានផ្តល់ភាពស្រប "ច្បាប់" ដល់ការរំលោភអំណាច ការធ្វើសេចក្តីសំរេចតាមទំនើងចិត្ត និងការលើកលែងទោសឱ្យជនដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ។

២១. ដូចជាករណីដែលពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងជាច្រើន នៅក្រោយពេលនៃការបង្កើតឱ្យមានសន្តិភាពនៅអំឡុងពេលប៉ុន្មានឆ្នាំនេះ ការបង្កើតឱ្យមាននីតិរដ្ឋ គឺជាបញ្ហាអាទិភាពមួយសំរាប់ទីភ្នាក់ងារនៃប្រទេសអ្នកផ្តល់ជំនួយ និងទីភ្នាក់ងារអភិវឌ្ឍន៍នានានៅក្នុងប្រទេសកម្ពុជា ។ រាល់កិច្ចខិតខំប្រឹងប្រែងទាំងនេះបានទទួលលទ្ធផល និងប្រសិទ្ធិភាពតិចតួចក្នុងការសំរេចសមិទ្ធិផលពិតប្រាកដសំរាប់ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ក្នុងរូបភាពនៃការប្រើប្រាស់ប្រព័ន្ធតុលាការ ឬការបង្កើតឱ្យមានស្ថាប័នតុលាការមួយឯករាជ្យ មិនលំអៀង និងមិនពុករលួយ ។ នៅក្នុងទសវត្សកន្លងមកនេះ គេឃើញមានការបន្តត្រួតពិនិត្យដោយអំណាចនីតិប្រតិបត្តិទៅលើស្ថាប័នតុលាការ និងស្ថាប័នច្បាប់សំខាន់ៗ ដទៃទៀត ហើយអន្តរាគមន៍ត្រូវបានធ្វើឡើងដោយមិនមានការវិភ័យ និងការយល់ដឹងអំពីបញ្ហាដែលកើតមាន និងឧបសគ្គក្នុងការធ្វើកំណែទម្រង់ពិតប្រាកដ ។ ឧបសគ្គធំបំផុតក្នុងការបង្កើតឱ្យមានឯករាជ្យភាពតុលាការនោះ គឺតុលាការបន្តដំណើរការការងាររបស់ខ្លួនជាសាខានៃអំណាចនីតិប្រតិបត្តិ ការអនុវត្តដែលមានលក្ខណៈជាការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌នៅប្រទេសកម្ពុជានៅក្នុងទសវត្សឆ្នាំ១៩៨០ ហើយដែលបានចាក់ឫសយ៉ាងជ្រៅ ។ នៅក្នុងទសវត្សឆ្នាំ១៩៩០ក៏បានផ្តល់ឱកាសជាច្រើនសំរាប់អំពើពុករលួយ និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ។ ជាថ្មីម្តងទៀត ការកសាងសមត្ថភាព និងដំណោះស្រាយផ្នែកបច្ចេកទេសតែមួយគត់នោះ នឹងមិនអាចដោះស្រាយបញ្ហាទាំងនេះបានឡើយ ។

២២. មានករណីជាច្រើននៅក្នុងឆ្នាំ២០០៤ បង្ហាញឱ្យឃើញថាបញ្ហាទាំងអស់នេះនៅតែកើតមាន ។ ករណីមួយដែលជាតួយ៉ាងនៃបញ្ហានីទណ្ឌភាព និងតួនាទីរបស់តុលាការ នោះគឺករណីលោក ជា វិជ្ជា ប្រធានសហជីពកម្មករត្រូវបានគេបាញ់សំលាប់ក្នុងរូបភាពជាការស៊ីឈ្នួលសំលាប់មនុស្សនៅកណ្តាលរាជធានីភ្នំពេញកាលពីព្រឹកថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ ។ នៅពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៤ លោក ហេង ធីរិទ្ធិ ចៅក្រមស៊ើបអង្កេតនៃតុលាការ

ក្រុងភ្នំពេញបានចេញដីកាលើកលែងចោទប្រកាន់ ដោយសារមិនមានភស្តុតាងគ្រប់គ្រាន់ ដល់បុរស២ នាក់ដែលត្រូវបានចាប់ខ្លួនពីបទមនុស្សឃាដ ។

២៣. បើតាមរបាយការណ៍ដែលអាចជឿទុកចិត្តបានថា គាត់បានចេញដីកាផ្ទុយនឹងសេចក្តីណែនាំលំអិតពីមន្ត្រីជាន់ខ្ពស់មួយរូបនៃរដ្ឋាភិបាលដែលសុំឱ្យបញ្ជូនករណីនេះទៅជំនុំជំរះ ។ ព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ចំពោះដីកានោះ ។ នៅពីថ្ងៃទី២២ ខែមីនា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានសំរេចដាក់វិន័យចៅក្រមរូបនេះ ដោយមូលហេតុផ្សេងពីករណីនេះ ។ នៅក្នុងខែកក្កដា ចៅក្រមរូបនេះត្រូវបានគេផ្លាស់ទៅធ្វើការនៅតំបន់ឆ្ងាយ ក្នុងខេត្តស្ទឹងត្រែង ។ កាលពីថ្ងៃទី៨ ខែកក្កដា លោកតំណាងពិសេសបានចេញសេចក្តីថ្លែងការណ៍មួយ ដែលក្នុងនោះលោកបានសំដែងសេចក្តីព្រួយបារម្ភអំពីភាពមិនប្រក្រតីជាច្រើនកើតមានក្នុងការស៊ើបអង្កេត និងការចោទលើករណីនេះ ។ លោកក៏បានលើកយកកង្វល់របស់លោកជំរាបមន្ត្រីជាន់ខ្ពស់នានានៃរដ្ឋាភិបាល នៅក្នុងអំឡុងបេសកកម្មរបស់លោក ។ ជនសង្ស័យត្រូវបានឃុំខ្លួនមុនសវនាការលើសរយៈពេលអតិបរិមា៦ ខែដែលច្បាប់កម្ពុជាបានអនុញ្ញាត ដើម្បីរង់ចាំការស៊ើបអង្កេតបន្ថែម ។

២៤. សាធារណៈជនទូទៅនៅក្នុងប្រទេសកម្ពុជាមានទស្សនៈថា តុលាការពុករលួយ ហើយមិនមានភាពស្មើគ្នាចំពោះមុខច្បាប់ ដែលបញ្ហានេះស្តែងឡើងដោយករណី២ នៅក្នុងតុលាការក្រុងភ្នំពេញ កាលពីខែមីនា ឆ្នាំ២០០៤ កន្លងទៅនេះ ។ ការជំនុំជំរះ និងវិនិច្ឆ័យទោសឈ្មោះ នឹម សុភា ក្មួយប្រុសរបស់លោកនាយករដ្ឋមន្ត្រី គឺជាតួយ៉ាងមួយបង្ហាញថាតុលាការលំអៀងជនដែលមានបុព្វសិទ្ធិ និងបក្សពួកអ្នកមានអំណាច ។ កាលដែលតុលាការមិនចង់ប្រកាសសាលក្រមអំពីពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជននេះ ទើបភាពអយុត្តិធម៌កើតមាននៅក្នុងករណីនេះ រីឯចំណាត់ការរបស់តុលាការទៀតសោតក៏ផ្ទុយនឹងច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិដែរ ។ ជនជាប់ចោទត្រូវបានសាក្សីជាច្រើននាក់ស្គាល់ថាជាជនដែលបានធ្វើការបាញ់រះទៅលើហ្វូងមនុស្ស បន្ទាប់ពីគ្រោះថ្នាក់ចរាចរមួយបានកើតឡើង កាលពីខែតុលា ឆ្នាំ២០០៣ ។ នៅក្នុងហេតុការណ៍នោះមានមនុស្សពីរនាក់ស្លាប់ និងបួននាក់ទៀតត្រូវរងរបួស ។ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទមនុស្សឃាតដោយចេតនា ។ តុលាការដំបូងមិនបានជូនដំណឹងជាមុនថាករណីនេះត្រូវបើកសវនាការនៅថ្ងៃទី១១ ខែមីនានោះទេ ហើយសវនាការនេះត្រូវបានធ្វើឡើងជាសំងាត់ ។ សាច់ញាតិរបស់ជនរងគ្រោះបានទទួលសំណងជម្ងឺចិត្តជាប្រាក់សរុបចំនួន៨.០០០ ដុល្លារ ហើយសន្យាថាមិនផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការឡើយ ។ ជនម្នាក់ទៀតដែលនគរបាលមិនបានធ្វើការចាប់ខ្លួន ត្រូវបានតុលាការចាប់ឱ្យទទួលខុសត្រូវ និងកាត់ទោសដោយកំបាំងមុខ ។ នឹម សុភា ត្រូវតុលាការផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល១៨ ខែ បន្ទាប់ពីបទចោទប្រកាន់មកលើរូបគាត់ត្រូវបានបន្ថយមកនៅត្រឹមបទមនុស្សឃាតដោយអចេតនា ។ កាលពីថ្ងៃទី២៦ ខែសីហា នៅក្នុងសវនាមួយផ្សេងទៀតជាសំងាត់នៅសាលាឧទ្ធរណ៍ ជនជាប់ចោទរូបនេះត្រូវបានគេលើកលែងចោទប្រកាន់ទាំងស្រុង ។

ព្រះរាជអាជ្ញាមិនបានប្ដឹងឧទ្ធរណ៍ចំពោះករណីនេះទេ ទោះបីជាមានការរំលោភដ៏ច្បាស់ក្រឡែកលើច្បាប់ជាតិ និងច្បាប់អន្តរជាតិក៏ដោយ ។ ផ្ទុយទៅវិញ នៅថ្ងៃដដែលនោះ បន្ទាប់ពីការកាត់សេចក្ដី នឹម សុភា រួចមក តុលាការក្រុងភ្នំពេញបានជំនុំជំរះករណីរបស់ឈ្មោះ កុល វិនទ្បៃ ក្នុងបទលួចលុយចំនួន២៧០០រៀល ដែលប្រមាណជា០,៦៥ ដុល្លារ ។ ជនល្មើសរូបនេះត្រូវបានតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគាររយៈពេលបួនឆ្នាំ បន្ទាប់ពីម្ដាយរបស់ជននេះគ្មានលទ្ធភាពបង់ប្រាក់ចំនួន១.០០០ ដុល្លារ ជាថ្នូរដល់ការដោះលែងឱ្យរួចខ្លួន ។

២៥. ក្នុងករណីបែបនេះ គឺមិនមានការងឿងឆ្ងល់ទេ បើតាមការសិក្សាស្រាវជ្រាវថ្មីៗនេះបានបញ្ជាក់ទៅលើការស្ទង់មតិពីខាងដើមថា តុលាការគឺជាស្ថាប័នរដ្ឋមួយ ដែលប្រជាពលរដ្ឋកម្ពុជាមានជំនឿទុកចិត្តតិចតួចបំផុត ។ លោកតំណាងពិសេសបានលើកយកកង្វល់របស់លោកមកពិភាក្សាជាច្រើនលើកច្រើនសារជាមួយលោកនាយករដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់នានានៃរដ្ឋាភិបាល ដោយលោកបានស្នើយ៉ាងទទូចសុំឱ្យតុលាការបញ្ចប់ការអនុវត្តទាំងឡាយ ដែលរើសអើង ហើយលោកសង្ឃឹមថា កិច្ចដំណើរការកំណែទម្រង់ នឹងអាចដោះស្រាយបញ្ហាទាំងនេះបាន ។

២៦. វិជ្ជាជីវៈច្បាប់មួយដែលខ្លាំង ហើយឯករាជ្យ គឺជាកត្តាសំខាន់សំរាប់ការធានាការពារ និងលើកស្ទួយសិទ្ធិមនុស្ស និងការធ្វើកែទម្រង់ប្រព័ន្ធច្បាប់ ។ តែគួរឱ្យសោកស្ដាយណាស់ ដោយសារមានការជ្រៀតជ្រែកដល់ឯករាជ្យភាពនៃគណៈមេធាវី ។ នៅឆ្នាំកន្លងទៅថ្មីៗនេះ មានមន្ត្រីជាន់ខ្ពស់មួយចំនួននៃរដ្ឋាភិបាលបានផ្ដល់អំណោយឯកជនយ៉ាងច្រើនទៅឱ្យគណៈមេធាវី ។ នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីពីររូប និងរដ្ឋលេខាធិការមួយរូបនៃក្រសួងមហាផ្ទៃត្រូវបានទទួលជាសមាជិកគណៈមេធាវីនៅពីខែកញ្ញា ឆ្នាំ២០០៤ ហើយបានទទួលអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈច្បាប់ទៀតផង ទោះជាមន្ត្រីទាំងនោះ មិនមានលក្ខណៈសម្បត្តិវិជ្ជាគ្រប់គ្រាន់ និងមិនធ្លាប់ប្រកបវិជ្ជាជីវច្បាប់ក៏ដោយ ។ ការទទួលមន្ត្រីទាំងនេះជាសមាជិកបានលេញឡើងនូវការអះអាងថា គណៈមេធាវីប្រកាន់បក្សពួក មិនឯករាជ្យ និងធ្វើតាមទំនើងចិត្តក្នុងការទទួលឱ្យចូលជាសមាជិករបស់ខ្លួន ។

២៧. នៅក្នុងសកម្មភាពមួយដែលអ្នកខ្លះបានធ្វើការបកស្រាយថា ជាប្រតិកម្មដល់ការរិចរិលនៃឯករាជ្យភាពសមាជិកគណៈមេធាវីបានជ្រើសតាំងមេធាវី និងអ្នកការពារក្ដីម្នាក់មកពីសង្គមស៊ីវិល ដើម្បីធ្វើជាប្រធានគណៈមេធាវីកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៤ ។ លទ្ធផលនៃការបោះឆ្នោតនេះ មានការតវ៉ាគ្នាដោយអ្នកគាំទ្រប្រធានចាស់ ។ សាលាឧទ្ធរណ៍បានបើកសវនាការជាសំងាត់ កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ហើយបានសំរេចថា ប្រធានចាស់ត្រូវបន្តកាន់តំណែងរយៈពេលបីខែតទៅទៀត ហើយនៅក្នុងអំឡុងពេលនេះ គាត់ត្រូវរៀបចំឱ្យមានការបោះឆ្នោតជ្រើសតាំងប្រធានថ្មី ទោះបីជាសេចក្ដីសំរេចមិនបានចែងដាក់លាក់ថាត្រូវតែរៀបចំឱ្យមានការបោះឆ្នោតក៏ដោយ ។ នៅក្នុងសេចក្ដីថ្លែងការណ៍មួយដែលគាំទ្រដោយសមាជិកភាគច្រើនរបស់ខ្លួន គណៈមេធាវីបានប្រកាសកាលពីថ្ងៃទី២៤ ខែ

វិធ្វិកា ថាខ្លួនមិនមិនទទួលខុសត្រូវចំពោះសេចក្តីសំរេច ឬសកម្មភាពណាមួយដែលធ្វើឡើងដោយប្រធានចាស់ក្នុងនាម គណៈមេធាវី ហើយក៏មិនទទួលស្គាល់សេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ដែរ ។

២៨. កាលពីខែកក្កដា ឆ្នាំ២០០២ ប្រទេសអ្នកផ្តល់ជំនួយ និងរដ្ឋាភិបាល បានយល់ព្រមថាវិស័យជាគន្លឹះសំរាប់ការធ្វើកំណែទម្រង់វិស័យយុត្តិធម៌ នឹងរៀបចំឡើងនៅក្នុងខែតុលា ឆ្នាំ២០០២ ហើយថាសកម្មភាពនេះ នឹងដៅចំពោះការប្រឆាំងអំពើពុករលួយ ។ ករណីទាំងអស់ដែលបានរាយការណ៍ថាមានអំពើពុករលួយនឹងត្រូវបានធ្វើការស៊ើបអង្កេតជាបន្ទាន់ និងផ្តន្ទាទោសក្នុងក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ ហើយច្បាប់ប្រឆាំងអំពើពុករលួយនឹងត្រូវដាក់ជូនរដ្ឋសភានៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ ។ រហូតមកទល់ពេលនេះ មានតែការកំណត់ពេលអនុវត្តមួយ ក្នុងចំណោមការកំណត់ពេលអនុវត្តចំនួនប្រាំ ដែលបានព្រមព្រៀងនៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់កាលពីខែមិថុនា ឆ្នាំ២០០២ ។ ឯកសារយុត្តិសាស្ត្រសំរាប់ការធ្វើកំណែទំរង់ច្បាប់ និងប្រព័ន្ធតុលាការ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ ជាមួយសេចក្តីព្រាងផែនការសកម្មភាព ឯកសារទាំងពីរនេះត្រូវបានលោកតំណាងពិសេសលើកឡើងនៅក្នុងរបាយការណ៍លើកមុន ។

២៩. ស្ថាប័ននានាដែលបានចូលរួមក្នុងកិច្ចដំណើរការរៀបចំផែនការ និងបណ្តុះបណ្តាលវិស័យយុត្តិធម៌បានបង្ហាញថាមានការរីកចំរើនខ្លះហើយ នៅក្នុងពេលធ្វើរបាយការណ៍នេះ ។ ការងាររបស់អង្គភាពគ្រប់គ្រងគំរោងនៃអង្គភាពសំរបសំរួលអចិន្ត្រៃយ៍ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ឃើញថាមានការរីកចំរើនប្រកបដោយប្រសិទ្ធិភាពគួរឱ្យកត់សំគាល់ ហើយបានអនុម័តនូវកិច្ចដំណើរការពិគ្រោះយោបល់ ។

៣០. នៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់សំរាប់ប្រទេសកម្ពុជា ដែលបានធ្វើឡើងនៅរាជធានីភ្នំពេញ កាលពីខែធ្នូ ឆ្នាំ២០០៤ កន្លងទៅនេះ រដ្ឋាភិបាល និងប្រទេសអ្នកផ្តល់ជំនួយបានព្រមព្រៀងថាគណៈរដ្ឋមន្ត្រី តាមការប្រញាប់ គួរអនុម័ត និងដាក់ជូនរដ្ឋសភានូវក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ។ ក្រុមពិគ្រោះយោបល់ក៏បានយល់ស្របថា ច្បាប់ទាំងនេះគួរតែរៀបចំឡើង តាមរយៈកិច្ចដំណើរការមួយគួរជាទីពេញចិត្ត និងមានមនុស្សចូលរួមច្រើន ហើយស្របទៅនឹងរដ្ឋធម្មនុញ្ញ និងអនុវត្តទាំងឡាយដែលប្រសើរបំផុតរបស់អន្តរជាតិ ដូចមានចែងនៅក្នុងសទ្ធិសញ្ញាសិទ្ធិមនុស្ស និងលិខិតុបករណ៍អន្តរជាតិដទៃទៀត ដូចជាគោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ និងគោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា ។ លោកតំណាងពិសេសសង្ឃឹមថា រដ្ឋាភិបាលនឹងផ្តល់អាទិភាពដល់ច្បាប់ដ៏សំខាន់នេះនៅក្នុងឆ្នាំ

២០០៥ ហើយច្បាប់ទាំងនេះត្រូវស្របតាមបទប្បញ្ញត្តិនានានៃសទ្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលប្រទេសកម្ពុជាជាប់កាតព្វកិច្ចត្រូវអនុវត្តតាម ។

៣១. សាលាភូមិន្ទបណ្តុះបណ្តាលមេធាវី ចៅក្រម និងព្រះរាជអាជ្ញាមានការជឿនលឿនទៅមុខក្នុងការងាររបស់ខ្លួន ។ និស្សិតជំនាន់ទីមួយ នឹងបញ្ចប់វគ្គបណ្តុះបណ្តាលរបស់ខ្លួននៅក្នុងឆ្នាំ២០០៥ នេះ ហើយត្រៀមខ្លួនដើម្បីទទួលការតែងតាំង ។ សាលាបានរៀបចំទីតាំងសំរាប់បណ្តុះបណ្តាលចៅក្រមដែលមាន សមត្ថភាពបច្ចេកទេសឯករាជ្យ ប្តេជ្ញាចិត្តធ្វើជាអ្នកការពារនីតិរដ្ឋ និងប្រឆាំងការជ្រៀតជ្រែងដោយអំណាចនីតិប្រតិបត្តិ និងអំពើពុករលួយ ។ ទោះជាដូច្នេះក្តី ការសន្យានេះក៏នៅមានភាពមន្ទិលសង្ស័យ ដោយការចោទប្រកាន់ថា មានអំពើពុករលួយ និងការជ្រៀតជ្រែកពីអំណាចនីតិប្រតិបត្តិ នៅក្នុងកិច្ចដំណើរជ្រើសរើសនិស្សិតឱ្យចូលរៀន ។

៣២. វិស័យយុត្តិធម៌អាចរីកចំរើនតិចតួចបាន លុះត្រាតែសេចក្តីសំរេចខាងនយោបាយសំរាប់ការធ្វើកំណែទម្រង់ត្រូវបានធ្វើនៅថ្នាក់កំពូលនៃរដ្ឋាភិបាល ។ សភាពការណ៍ក្នុងវិស័យជាច្រើនស្ថិតក្នុងភាពព្រិចស្រពិលនៅឡើយ តាំងពីលោកតំណាងពិសេសត្រូវបានតែងតាំងជាលើដំបូង កាលពីខែសីហា ឆ្នាំ២០០០ ។ ការរីកចំរើនអាចកើតមាននៅពេលដែលតុលាការទាំងអស់នៃប្រទេសកម្ពុជា អាចសំរេចសេចក្តីទៅតាមច្បាប់ ដោយមិនភ័យខ្លាចមានការសងសឹក និងការដាក់ទណ្ឌកម្មខាងវិន័យដោយមូលហេតុនយោបាយ និងនៅពេលដែលតុលាការចាប់ផ្តើមចាត់ទុកប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ។ ប្រឆាំងអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ ហើយត្រូវគោរពគោលការណ៍បែងចែកអំណាចជាដាច់ខាត ។

៣៣. លោកតំណាងពិសេសគាំទ្រដល់វិធីដំណោះស្រាយរបស់ទីភ្នាក់ងារនៃប្រទេសអ្នកផ្តល់ជំនួយ និងរដ្ឋាភិបាលនានា ដែលផ្តោតលើសេចក្តីត្រូវការឱ្យមានការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាពិសេសកម្មវិធីជំនួយផ្នែកច្បាប់ និងការអប់រំច្បាប់ដល់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលគ្មានលទ្ធភាព ។ ការផ្តួចផ្តើមគំនិតពាក់ព័ន្ធផ្សេងៗរួមមានការអប់រំច្បាប់ ការជួយឱ្យសហគមន៍មូលដ្ឋានយល់ដឹងអំពីសិទ្ធិស្របច្បាប់របស់ខ្លួន ហើយជួយពួកគេ និងតំណាងរបស់គេឱ្យមានមធ្យោបាយ និងចំណេះដឹងដើម្បីការពារសិទ្ធិរបស់ខ្លួន និងដើម្បីចងក្រងឯកសារ និងផ្សព្វផ្សាយជាសាធារណៈនូវការរំលោភផ្សេងៗដែលកើតមាន ។ លោកតំណាងពិសេសគាំទ្រផងដែរដល់ការសិក្សាស្រាវជ្រាវដើម្បីផ្តល់ពត៌មានស្តីពីការបង្កើតគោលនយោបាយនៅក្នុងវិស័យនេះ ឧទាហរណ៍ដូចជាការសិក្សាស្រាវជ្រាវអំពីហេតុប៉ះពាល់នៃយន្តការដោះស្រាយជំលោះក្រៅប្រព័ន្ធតុលាការនៅថ្នាក់មូលដ្ឋានក្នុងការស្វែងរកយុត្តិធម៌ ហេតុប៉ះពាល់នៃគោល-នយោបាយវិមជ្ឈការដល់ការដោះស្រាយជំលោះ និងការស្វែងរកយុត្តិធម៌នៅថ្នាក់ឃុំ សង្កាត់ និងហេតុប៉ះពាល់គ្នារវាងវិស័យយុត្តិធម៌ផ្លូវការ និងក្រៅផ្លូវការ ។

## ឃ. ការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម

៣៤. ការរីកចំរើនមានកំរិតនៅក្នុងឆ្នាំ២០០៤ ក្នុងការរៀបចំបង្កើតឱ្យមានអង្គជំនុំជំរះ ដើម្បីកាត់សេចក្តីជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ការយឺតយ៉ាវនេះ មួយចំណែកគឺដោយសារមានភាពទល់ច្រកខាងនយោបាយ ។ កាលពីថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៤ រដ្ឋសភាបានអនុម័តជាឯកច្ឆ័ន្ទលើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតឱ្យមានអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ហើយបានអនុម័តលើវិសោធនកម្មមាត្រាមួយចំនួននៃច្បាប់បង្កើតអង្គជំនុំជំរះវិសាមញ្ញ ឆ្នាំ២០០១ ដើម្បីឱ្យស្របតាមកិច្ចព្រមព្រៀង ។ ច្បាប់នេះត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃ ទី២៧ ខែតុលា បន្ទាប់ពីព្រឹទ្ធសភាបានអនុម័តយល់ព្រមរួចមក ។

៣៥. ការពិភាក្សាជាច្រើននៅក្នុងរយៈពេលជាងមួយឆ្នាំនេះ បានផ្តោតការយកចិត្តទុកដាក់លើបញ្ហាថវិកា បន្ទាប់ដំណើរទស្សនកិច្ចមកកាន់រាជធានីភ្នំពេញ កាលពីខែមីនា ឆ្នាំ២០០៤ នៃអ្នកសំរបសំរួលជំនួយអង្គការសហប្រជាជាតិដល់ការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ដែលនៅក្នុងអំឡុងពេលនោះ ថវិការដែលបានគ្រោងទុកមានប្រមាណជា៦០ លានដុល្លារ ។ ចាប់ពីពេលនោះមក រដ្ឋជាសមាជិកមួយចំនួនបានកាត់បន្ថយថវិកាជាច្រើនពីក្នុងថវិការដែលបានស្នើសុំ ។ របាយការណ៍របស់លោកអគ្គលេខាធិការ ដាក់ជូនមហាសន្និបាតអ.ស.បលេខ (A/59/432 និងឧបសម្ព័ន្ធទី១) ចែងលំអិតអំពីសេចក្តីត្រូវការធនធាន និងការប្រើប្រាស់ធនធាន ព្រមទាំងគូសបញ្ជាក់ពីដំណាក់កាលជាបន្តបន្ទាប់ដែលត្រូវអនុវត្ត ។ នៅពេលសរសេររបាយការណ៍នេះ ក្រុមការងាររបស់អង្គការសហប្រជាជាតិ ទើបបានបញ្ចប់ដំណើរទស្សនកិច្ចមួយទៀតមកកាន់រាជធានីភ្នំពេញ ប៉ុន្តែមិនទាន់មានរបាយការណ៍នោះនៅឡើយទេ ។

៣៦. លោកតំណាងពិសេសស្នើយ៉ាងទទូចដល់រដ្ឋាភិបាលនៃប្រទេសអ្នកផ្តល់ជំនួយនានា សុំឱ្យផ្តល់ឱ្យបានឆាប់រហ័សនូវថវិការចាំបាច់ នៅពេលដែលកិច្ចព្រមព្រៀងស្តីពីថវិការត្រូវបានសំរេច ដើម្បីអាចបង្កើតអង្គជំនុំជំរះវិសាមញ្ញ និងដំណើរការការកាត់សេចក្តីបាន ។ ការកាត់សេចក្តីមិនមែនការគៀបសង្កត់របស់បរទេសមកលើកម្ពុជាទេ ។ ដូចលោកតំណាងពិសេសបានគូសបញ្ជាក់ពីមុនថា មានមនុស្សច្រើននាក់ បើមិនមែនប្រជាពលរដ្ឋកម្ពុជាភាគច្រើននោះទេ ចង់ឱ្យការកាត់សេចក្តីនេះជាមធ្យោបាយដើម្បីកំណត់ និងទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ហើយដើម្បីឱ្យបានយល់ថា ហេតុអ្វីបានជាកើតមានឧក្រិដ្ឋកម្មទាំង

នេះ ។ ត្រូវខិតខំប្រឹងប្រែងផងដែរ ដើម្បីបង្កើនជាអតិបរិមានូវសក្តានុពលសំរាប់ការកាត់សេចក្តី ដើម្បីឱ្យមានលទ្ធផលវិជ្ជមានរយៈពេលវែងសំរាប់ប្រព័ន្ធច្បាប់ និងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ។

## ង. សេរីភាពជាមូលដ្ឋាន

៣៧. លោកតំណាងពិសេសនៅតែមានកង្វល់អំពីការរិតត្បិតដល់សេរីភាពនៃការប្រជុំ និងក្នុងការបង្កើតសមាគមដែលត្រូវបានធ្វើជារៀងរហូតមក ចាប់តាំងពីមានកុប្បកម្មប្រឆាំងនឹងថៃ កាលពីខែមករា ឆ្នាំ២០០៣ លើកលែងនៅក្នុងអំឡុងពេលយុទ្ធនាការផ្លូវការរយៈពេលមួយខែ សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងឆ្នាំ២០០៣ប៉ុណ្ណោះ ។ លោកតំណាងពិសេសដឹងថា មានសំណើរជាង៣០ ករណីដែលស្នើសុំធ្វើការប្រមូលផ្តុំដោយសន្តិវិធីត្រូវបានសាលាក្រុងភ្នំពេញបដិសេធនៅក្នុងរយៈពេលនោះ ដែលការបដិសេធទាំងនេះជារឿយៗធ្វើឡើងដោយខ្វះការពិចារណា ហើយជួនកាលមិនមានបញ្ជាក់អំពីហេតុផលណាមួយឡើយ នេះគឺជាការរំលោភលើច្បាប់ស្តីពីបាតុកម្ម ។ នគរបាលបានបណ្តោយឱ្យការប្រមូលផ្តុំ២ដែលគ្មានការអនុញ្ញាតបន្តធ្វើ ។ ការប្រមូលផ្តុំផ្សេងទៀតត្រូវបានរារាំង ឬបំបែកដោយប្រើកំលាំង ។ សេរីភាពក្នុងការប្រជុំ ក៏ត្រូវបានជ្រៀតជ្រែកដោយវិធីផ្សេងៗ ដូចជាតាមរយៈការបំភិតបំភ័យបាតុករ ឬអ្នកផ្តល់ទីកន្លែងសំរាប់ធ្វើការប្រមូលផ្តុំ ។ មានការព្រួយបារម្ភអំពីសន្ទស្សន៍ផ្សេងៗ ដែលសេរីភាពក្នុងការប្រមូលផ្តុំ ការបង្កើតសមាគម និងការដើរហើរត្រូវបានរិតត្បិតច្រើនថែមទៀត នៅទូទាំងប្រទេសកម្ពុជា ។

៣៨. បញ្ញត្តិខ្លះនៃច្បាប់បាតុកម្មមិនស្របតាមរដ្ឋធម្មនុញ្ញ ព្រោះបញ្ញត្តិទាំងនោះផ្ទុយទៅនឹងសេរីភាពក្នុងការប្រជុំ និងការធ្វើបាតុកម្ម មានការព្រួយបារម្ភដូចគ្នានេះដែរថាអាជ្ញាធរ ជារឿយៗតែងបំពានលើបទប្បញ្ញត្តិនៃច្បាប់ ឬអនុវត្តតាមរបៀបមួយដែលរំលោភសិទ្ធិដែលការពារដោយរដ្ឋធម្មនុញ្ញ ។ ជួនកាល ហេតុផលដែលបានយកមកប្រើគឺមិនមែនជាហេតុផលច្បាប់អនុញ្ញាត ហើយនៅពេលខ្លះទៀត មិនមានភស្តុតាងពិតប្រាកដ ដើម្បីការពារហេតុផលដែលលើកឡើងនោះឡើយ ។ ត្រូវយល់ដឹងឱ្យបានច្រើនពីហេតុការណ៍ ដែលប្រទេសភាគច្រើនតម្រូវឱ្យធ្វើការជូនដំណឹងទៅអាជ្ញាធរជាមុន គោលបំណងនោះគឺមិនមែនដើម្បីស្នើសុំការអនុញ្ញាតធ្វើបាតុកម្មនោះទេ ប៉ុន្តែនេះគ្រាន់តែជាការផ្តល់ឱ្យមានកិច្ចដំណើរការចរាចរគ្នាតែប៉ុណ្ណោះ ឧទាហរណ៍ដូចជាពេលវេលា និងផ្លូវដែលត្រូវធ្វើការប្រមូលផ្តុំនៅទីសាធារណៈជាដើម ។ ការរិតត្បិតជាច្រើនត្រូវបានធ្វើដោយខ្វះការពិចារណា។ ក្បួនធម្មយាត្រាដើម្បីសន្តិភាពដោយព្រះសង្ឃចំនួន ១០ អង្គ មិនត្រូវបានអនុញ្ញាតឱ្យធ្វើ ដោយផ្អែកលើមូលហេតុថាជាការធ្វើឱ្យខូចដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ដូចគ្នានេះដែរ គឺបាតុកម្មប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារដោយជនរងគ្រោះ ដោយអំពើហឹង្សានេះក៏មិនត្រូវបានអនុញ្ញាតឱ្យធ្វើដែរ ។ ប៉ុន្តែបាតុកម្មមួយដែលធ្វើឡើងដោយក្រុមអ្នកគាំទ្ររដ្ឋាភិបាល ក្មេងវត្តអ្នកបញ្ញាវ័ន្ត និង សមាគមនិស្សិត ដែលជាប់ពាក់ព័ន្ធនឹងអំពើហឹង្សាកន្លងមកត្រូវបានអនុញ្ញាតឱ្យធ្វើ ។

៣៩. រហូតមកទល់ឆ្នាំ១៩៩១ ទើបច្បាប់ស្តីពីបាតុកម្មត្រូវបានព្រាងឡើងវិញ ដើម្បីឱ្យស្របតាមរដ្ឋធម្មនុញ្ញកម្ពុជា និងកាតព្វកិច្ចរបស់ខ្លួនក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ លោកតំណាងពិសេសស្នើយ៉ាងទទូចសុំឱ្យអាជ្ញាធរគ្រប់ជាន់ថ្នាក់មេត្តាអនុវត្តច្បាប់ឱ្យបានស្របតាមសិទ្ធិទាំងឡាយដែលការពារដោយរដ្ឋធម្មនុញ្ញ និង អនុញ្ញាតឱ្យមានការលើកលែងមួយចំនួន តែត្រូវបញ្ជាក់ប្រាប់ពីហេតុផលពាក់ព័ន្ធឱ្យបានជាក់លាក់ និងច្បាស់លាស់ តាមច្បាប់កំណត់ ហើយហេតុផលត្រូវតែស្របទៅនឹងអង្គហេតុ ។ ការរិតត្បិតលើសេរីភាពក្នុងការប្រជុំត្រូវបានហាមឃាត់ លើកលែងតែការរិតត្បិតនោះធ្វើឡើងស្របច្បាប់សំរាប់គោលបំណងមួយចំនួនដែលមានកំរិត ដូចជាសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈដែលមានសមាមាត្រ ដើម្បីសំរេចគោលបំណងដែលពាក់ព័ន្ធ និងដែល "ចាំបាច់" នៅក្នុងសង្គមប្រជាធិបតេយ្យ ។

៤០. ដូចដែលលោកតំណាងពិសេសបានស្នើយ៉ាងទទូចនៅក្នុងរបាយការណ៍កន្លងមក និងនៅក្នុងអំឡុងបេសកកម្មរបស់លោកមកកាន់ប្រទេសកម្ពុជាកន្លងមក អាជ្ញាធរអនុវត្តច្បាប់ត្រូវតែបំពេញតួនាទីរបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ និងមានការទទួលខុសត្រូវនៅគ្រប់ពេលវេលាទាំងអស់ ក្នុងករណីដែលមានការប្រមូលផ្តុំធ្វើឡើងដោយគ្មានការអនុញ្ញាត ។ ប្រសិនជាការចាំបាច់បំផុតអាចបំបែកការប្រមូលផ្តុំនេះបាន ប៉ុន្តែមិនត្រូវប្រើកំលាំងហួសហេតុឡើយ ។ ទំហំនៃការប្រើប្រាស់កំលាំងត្រូវតែសមល្មម សមាមាត្រទៅនឹងការកំរាមកំហែងដែលបានបង្កឡើង ហើយត្រូវបានប្រើប្រាស់មធ្យោបាយមួយដែលបន្ថយជាអប្បរមានូវការខូចខាតទ្រព្យសម្បត្តិ ឬរបួសដល់មនុស្ស ហើយត្រូវប្រើប្រាស់សំរាប់តែមធ្យោបាយចុងក្រោយប៉ុណ្ណោះ ។ អាជ្ញាធរបានបន្តប្រើប្រាស់កំលាំងហួសហេតុនៅក្នុងឆ្នាំ២០០៤ ដើម្បីបំបែកហ្វូងបាតុករ ។ ក្នុងករណីជាច្រើន នគរបាលបានវាយដំបាតុករដោយប្រើដំបងជ័រ ឬដំបងឆក់ ដែលបណ្តាលអ្នកចូលរួម និងជួនកាលនគរបាលត្រូវរងរបួស ។ ប្រការដែលគួរឱ្យចាប់អារម្មណ៍នោះគឺ ក្នុងករណីភាគច្រើនអំពើហឹង្សាតែងកើតមាន បន្ទាប់ពីនគរបាលបានចូលជ្រៀតជ្រែកទៅក្នុងបាតុកម្ម ហើយបាតុករមិនជាប់ពាក់ព័ន្ធក្នុងអំពើហឹង្សា ឬអំពើល្មើសខាងព្រហ្មទណ្ឌណាមួយឡើយ ។

៤១. លោកតំណាងពិសេសកត់សំគាល់ដោយក្តីព្រួយបារម្ភអំពីករណីជាច្រើន ដែលអ្នកស្រុកធ្វើដំណើរទៅចូលរួមក្នុងការប្រមូលផ្តុំនៅក្នុងខេត្តផ្សេងទៀត ដើម្បីពិភាក្សានិងផ្លាស់ប្តូរយោបល់គ្នាលើបញ្ហាមួយចំនួនដូចជា បញ្ហាដីធ្លី និងបរិស្ថាន ត្រូវបាននគរបាលឃាត់ និងបានវិលត្រឡប់ទៅខេត្តរបស់ខ្លួនវិញ ។ លោកក៏បានកត់សំគាល់ថា កាលពីខែកក្កដាកន្លងទៅនេះ លោកអភិបាលខេត្តរតនគីរីបានប្រកាសថាសមាគមក្រៅរដ្ឋាភិបាលទាំងអស់ ត្រូវសុំការយល់ព្រមពីអាជ្ញាធរខេត្តជាមុនសិន មុននឹងចាកចេញពីខេត្តនោះ ។ សិទ្ធិដើរហើរដោយសេរីនៅក្នុងទឹកដីទាំងមូលនៃរដ្ឋមួយ ។ បើតាមលោកតំណាងពិសេសដឹង ការរិតត្បិតទាំងនេះគឺមិនស្របច្បាប់ទេ ហើយក៏មិនចាំបាច់ដែរនៅក្នុងសង្គមប្រជា-

ធិបតេយ្យ ។ សកម្មភាពទាំងនេះមានគោលដៅធ្វើការរិតត្បិតដល់សេរីភាពក្នុងការដើរហើរ ការសំដែងមតិ និងការបង្កើតសមាគម ។ ទាំងនេះមិនមែនជាសេរីភាព ដែលតាមធម្មតាត្រូវតែសុំការអនុញ្ញាតពីអាជ្ញារនោះទេ វាគឺជាសិទ្ធិដែលត្រូវតែលើកស្ទួយ និងអាចអនុវត្តបាន ។

## ច. ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ

៤២. កាលពីខែវិច្ឆិកា ឆ្នាំ២០០៤ លោកតំណាងពិសេសបានចេញរបាយការណ៍ស្តីពីដីសម្បទានគោលដៅសេដ្ឋកិច្ចទស្សនៈវិស័យខាងសិទ្ធិមនុស្ស ដោយផ្អែកលើការសិក្សាស្រាវជ្រាវធ្វើឡើង ដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា OHCHR/Cambodia ។ របាយការណ៍នោះបានពិនិត្យលើផលប៉ះពាល់នៃសម្បទានទាំងនេះ និងការដែលសម្បទានបានរួមចំណែកដល់ប្រាក់ចំណូលរដ្ឋទាំងមូលយ៉ាងណា និងផលប៉ះពាល់របស់សម្បទានទៅលើសិទ្ធិមនុស្ស និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរស់នៅក្នុង ឬជិតដីសម្បទានទាំងនោះ ។ លោកតំណាងពិសេសសង្ឃឹមថារបាយការណ៍ និងអនុសាសន៍នៃរបាយការណ៍នោះ នឹងជួយជាវិភាគទានសំរាប់ការយល់ដឹងថែមទៀតអំពីបញ្ហាទាំងនេះ និងជួយឱ្យមានការផ្លាស់ប្តូរគោលនយោបាយ និងទម្លាប់អនុវត្តទាំងឡាយដែលចាំបាច់ជាប្រយោជន៍សំរាប់ប្រទេសកម្ពុជា ប្រជាពលរដ្ឋក្រីក្ររបស់ខ្លួនរស់នៅជនបទ និងដើម្បីអនាគតនៃមនុស្សជំនាន់ក្រោយ ។

៤៣. បើតាមពតិមានដែលទទួលបានពីក្រសួងកសិកម្ម កាលពីខែកុម្ភៈ ឆ្នាំ២០០៣ គណៈរដ្ឋមន្ត្រីបានអនុម័តយល់ព្រមផ្តល់សម្បទានគោលដៅសេដ្ឋកិច្ចចំនួន៤០ ដែលគ្របដណ្តប់លើផ្ទៃដី៨០៩.២៩៦ ហិកតា ឬជាងបួនភាគរយនៃទឹកដីនៃប្រទេសកម្ពុជា ។ សម្បទានទាំងនេះត្រូវបានផ្តល់សំរាប់ធ្វើកសិកម្ម និងពាណិជ្ជកម្ម ហើយបានផ្តល់សិទ្ធិឱ្យសម្បទានិកមានសិទ្ធិប្រហាក់ប្រហែលគ្នានឹងសិទ្ធិរបស់កម្មសិទ្ធិករដែរ ខុសគ្នាត្រង់សិទ្ធិលក់ដូរ និងផ្ទេរកម្មសិទ្ធិតែប៉ុណ្ណោះ ។ សម្បទានសេដ្ឋកិច្ចមានរយៈពេលអតិបរិមា ៩៩ឆ្នាំ ទោះបីជាសម្បទានភាគច្រើនដែលបានផ្តល់កន្លងមកមានរយៈពេលកំណត់ត្រឹម៧០ឆ្នាំក៏ដោយ ។ ផ្ទៃដីអនុញ្ញាតមានទំហំអតិបរិមា១០.០០០ហិកតា ។ សម្បទានដែលបានផ្តល់នៅមុនពេលច្បាប់ភូមិបាលចូលជាធរមាន ហើយដែលមានទំហំធំជាងនេះត្រូវបន្ថយមកនៅត្រឹមតែ១០.០០០ហិកតា ទោះជាអាចមានការលើកលែងខ្លះក៏ដោយ ។

៤៤. អនុក្រឹត្យស្តីពីដីសម្បទានគោលដៅសង្គមកិច្ចដែលបានអនុម័ត នៅក្នុងខែមីនា ឆ្នាំ២០០៣ បានកំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធី និងយន្តការក្នុងការផ្តល់សម្បទានសំរាប់ធ្វើលំនៅស្ថាន និងធ្វើកសិកម្មសំរាប់ចិញ្ចឹមជីវិត ។ គោលបំណងគឺដើម្បីបង្វែរដីធ្លីដែលបានកាត់ចេញពីសម្បទានគោលដៅសេដ្ឋកិច្ច ទៅជាសម្បទានគោលដៅសង្គមកិច្ចវិញ ។ ទោះជា

ដូច្នេះក្តី ដីឯកជនរបស់រដ្ឋជាច្រើនដែលសមស្របសំរាប់សម្បទាន គោលដៅសង្គមកិច្ច បច្ចុប្បន្ននេះត្រូវបានផ្តល់ជាសម្បទានសំរាប់គោលដៅកសិកម្ម និងគោលដៅដទៃទៀត ។

៤៥. ទាមទារឱ្យមានអនុក្រឹត្យស្តីពីនីតិវិធីផ្តល់សម្បទានគោលដៅសេដ្ឋកិច្ច ការកាត់បន្ថយ និងការលើកលែងជាក់លាក់មួយចំនួន ចំពោះសម្បទានដែលមានផ្ទៃដីចាប់ពី១០.០០០ហិកតាឡើងទៅ ដែលនេះគឺជាការប្រញាប់ និងដែលបានអូសបន្លាយពេលយូរហើយ ។ អាស្រ័យដោយការផ្តល់សម្បទានអាចធ្វើបានតែលើដីឯកជនរបស់រដ្ឋ មិនមែនលើ " ដីសាធារណៈរបស់រដ្ឋ " ដែលមិនអាចលក់ដូរ ឬផ្ទេរសិទ្ធិបាននោះ ទើបអនុក្រឹត្យស្តីពីការធ្វើចំណាត់ថ្នាក់ " ដីសាធារណៈរបស់រដ្ឋ " និង " ដីឯកជនរបស់រដ្ឋ" ក៏ត្រូវការជាបន្ទាន់ដែរ ។

៤៦. នៅក្នុងអំឡុងបេសកកម្មរបស់លោក លោកតំណាងពិសេសបានជួបជាមួយតំណាងជនជាតិដើមភាគតិចកម្ពុជា ។ លោកមានសេចក្តីព្រួយបារម្ភថាជនជាតិដើមភាគតិច នឹងរិតតែងាយទទួលរងគ្រោះថែមទៀត ដោយការរឹបអូសយកដី និងការលក់ដូរ ឬការផ្ទេរសិទ្ធិស្របច្បាប់នៃដីធ្លីរបស់ពួកគេ ។ កិច្ចដំណើរការដើម្បីកំណត់ថាតើនរណាខ្លះជាជនជាតិដើមភាគតិច និងការកំណត់ព្រំដីរបស់ពួកគេបានអូសបន្លាយរយៈពេលយូរពេក ។ ទោះបីជាក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់កំពុងធ្វើការសិក្សាគំរោងសាកល្បង ដើម្បីគាំទ្រដល់ពង្រាងអនុក្រឹត្យ និងកិច្ចដំណើរការចេញប័ណ្ណកម្មសិទ្ធិសមូហភាពក្តីក៏មានការព្រួយបារម្ភជាច្រើនថា ដីនៅសេសសល់តិចតួចដើម្បីផ្តល់កម្មសិទ្ធិនៅពេលដែលអនុក្រឹត្យត្រូវបានព្រាង និងចាប់ផ្តើមដំណើរការចេញប័ណ្ណកម្មសិទ្ធិដីធ្លីនោះ ។ អនុក្រឹត្យនេះត្រូវតែអនុម័តឱ្យបានឆាប់បំផុត ហើយកិច្ចដំណើរការចេញប័ណ្ណកម្មសិទ្ធិសមូហភាពសំរាប់ដីសហគមន៍ជនជាតិដើមភាគតិចត្រូវតែធ្វើឱ្យបានចប់សព្វគ្រប់មុននឹងផ្តល់សម្បទានថ្មីណាមួយ ។

៤៧. លោកតំណាងពិសេសយល់ឃើញថា គោលនយោបាយសម្បទានមិនបានសំរេចជោគជ័យទេ ហើយត្រូវតែធ្វើការពិចារណាឡើងវិញ ។ គោលនយោបាយនេះមិនបានគិតគូរអំពីសុខមាលភាព និងសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋដែលពាក់ព័ន្ធឡើយ ហើយក៏មិនបានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រដែរ ហើយបាននាំទៅរកការប្លន់យកធនធានធម្មជាតិ ។ បញ្ហាទាំងនោះរួមមានការមិនបានពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋមូលដ្ឋាន ការមិនបានធ្វើការវាយតំលៃលើផលប៉ះពាល់បរិស្ថាន ការបដិសេធសិទ្ធិប្រើប្រាស់ដីជាប្រពៃណី ហើយនិងការមិនអនុញ្ញាតឱ្យប្រមូលអនុផលព្រៃឈើ ការជម្លៀសប្រជាពលរដ្ឋចេញពីលំនៅស្ថាន និងដីកសិកម្មរបស់ពួកគេ ការបាត់បង់របរចិញ្ចឹមជីវិតជាប្រពៃណីជាគុណប្រយោជន៍ដល់ការបង្កើតការងារមួយចំនួនដែលមានប្រាក់ឈ្នួលទាប ទំនាស់កើតមានរវាងក្រុមហ៊ុននានា និងប្រជាពលរដ្ឋមូលដ្ឋាន ហើយនិងមានការបំភិតបំភ័យពីកងសន្តិសុខប្រដាប់អាវុធ ហើយជួនកាលពីយោធិននៃកងយោធពលខេមរភូមិន្ទ ។ ប្រជាពលរដ្ឋកម្ពុជាទាំងមូលមិនបានទទួលអត្ថប្រយោជន៍ទេ ដោយសាររដ្ឋមិនបានទទួល

ប្រាក់ចំណូលជាដីកំភួនពីប្រាក់ឈ្នួល ប្រាក់កក់ ឬពន្ធផ្សេងៗទៀត ។ តាមការអនុវត្តជាក់ស្តែង សម្បទានត្រូវបានផ្តល់ដោយមិនតម្រូវឱ្យបង់ប្រាក់ឈ្នួល ដែលជាការរំលោភទៅនឹងមាត្រា៥១ នៃច្បាប់ភូមិបាល ។ ក្រៅពីការរកចំណេញពីដីធ្លីសម្បទានិកទទួលបានប្រាក់កំរៃមួយភាគធំពីការកាប់ឈើ ។ សម្បទានមួយភាគធំត្រូវបានផ្តល់នៅលើដីដែលមានព្រៃឈើស្រាប់ ហើយលោកតំណាងពិសេសបានធ្វើការសន្និដ្ឋានថា គេបានផ្តល់ជាមធ្យោបាយ ដើម្បីគេចវេសពីបញ្ញត្តិតឹងរឹងនៃច្បាប់ស្តីពីការគ្រប់គ្រងព្រៃឈើ ។

៤៨. រដ្ឋាភិបាលក៏បានអនុវត្តផ្ទុយនឹងច្បាប់ដែរ នៅក្នុងតំបន់ដទៃទៀត ។ រយៈពេលបីខែបន្ទាប់ពីការអនុម័តច្បាប់ភូមិបាលក្នុងខែវិច្ឆិកា ឆ្នាំ២០០៣ រដ្ឋាភិបាលបានចុះកិច្ចសន្យាមួយជាមួយក្រុមហ៊ុនគ្រីនស៊ី អ៊ីនដាស់ ស្ទ្រល ចំកាត់ (Green Sea Industrial Co Ltd) ដើម្បីធ្វើចំការម៉ៃសាក់ ដែលមានផ្ទៃដីទំហំដប់ដង នៃផ្ទៃដីអតិបរិមា១០០០០ ហិកតា ដែលច្បាប់បានអនុញ្ញាត ។ សម្បទានមួយទៀត ដែលបានផ្តល់ឱ្យក្រុមហ៊ុន គ្រីនរិច ចំកាត់ (The Green Rich Co. Ltd) នៅក្នុងខេត្តកោះកុង ក្រុមហ៊ុននេះតាំងនៅក្នុងព្រំប្រទល់នៃសួនឧទ្យានជាតិបុទុមសាគរ ដែលផ្ទុយនឹងបញ្ញត្តិច្បាប់ជាច្រើន ។

៤៩. ក្នុងករណីជាច្រើន ក្រុមហ៊ុនមួយចំនួនក៏បានរំលោភច្បាប់ភូមិបាល និងកិច្ចសន្យារបស់ខ្លួនដែរ ។ ក្រុមហ៊ុនទាំងនោះមិនបានអនុវត្តតាមច្បាប់តម្រូវឱ្យចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេល១២ (ដប់ពីរ) ខែបន្ទាប់ពីការផ្តល់សម្បទានទេ ។ ក្នុងករណីខ្លះ ក្រុមហ៊ុនបានធ្វើការដាំដុះដំណាំផ្សេងពីដំណាំដែលបានកំណត់នៅក្នុងកិច្ចសន្យារបស់ខ្លួន ។ ក្នុងករណីមួយ មានការលួចកាប់ឈើ និងការគេចពន្ធត្រូវបានធ្វើការចងជាឯកសារ ។ ទោះបីជាច្បាប់ភូមិបាលចែងថាសម្បទានសេដ្ឋកិច្ចអាចធ្វើការដកហូតវិញបាន តាមរយៈសេចក្តីសំរេចរបស់រដ្ឋាភិបាល នៅពេលដែលក្រុមហ៊ុនណាមួយមិនអនុវត្តតាមសេចក្តីតម្រូវផ្នែកច្បាប់ ហើយបើតាមព័ត៌មានដែលទទួលបានកន្លងមកមិនមានកិច្ចសន្យាណាមួយត្រូវបានធ្វើមោឃភាពនៅឡើយទេ ។

៥០. ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ តម្រូវឱ្យធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។ តាមការសិក្សាស្រាវជ្រាវរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (OHCHR/Cambodia) មិនមានសម្បទានណាមួយបានធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថានទេ ។ ការវាយតំលៃហេតុប៉ះពាល់សង្គមកិច្ច មិនទាន់តម្រូវឱ្យមានសំរាប់សម្បទានគោលដៅសេដ្ឋកិច្ចនៅឡើយ ។ នេះជាប្រការដែលគួរឱ្យសោកស្តាយ ហើយគួរតែធ្វើការកែប្រែ ។

៥១. ដូចជាវិស័យដទៃទៀតនៃសកម្មភាពរបស់រដ្ឋាភិបាលដែរ ការផ្តល់ដីសម្បទានគោលដៅសង្គមកិច្ច និងប្រព័ន្ធសម្បទានទូទៅ គឺឡោមព័ទ្ធទៅដោយភាពអាថិកំបាំង ។ សូម្បីតែព័ត៌មានសំខាន់ៗបំផុតមួយចំនួន ដូចជាកិច្ចសន្យាផែនទី និងអត្តសញ្ញាណនៃម្ចាស់ភាគហ៊ុនម្នាក់ៗ ក៏មិនបានរក្សាទុកសំរាប់សាធារណៈជនដែរ ។ មិនតែប៉ុណ្ណោះរដ្ឋាភិបាលមិនបានផ្សព្វផ្សាយជាទៀងទាត់អំពីប្រាក់ចំណូលដែលបានមកពីសម្បទានទាំងនេះទេ ។

៥២. លោកតំណាងពិសេសសូមស្វាគមន៍ចំពោះសន្ទរកថារបស់លោកនាយករដ្ឋមន្ត្រីដែលបានថ្លែង កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ក្នុងសន្ទរកថានោះ លោកប្រកាសថានឹងផ្អាកការផ្តល់កិច្ចសន្យាសម្បទានគោលដៅសេដ្ឋកិច្ចរហូតដល់មានបទបញ្ជាចាំបាច់សំរាប់អនុវត្តច្បាប់ត្រូវបានអនុម័ត និងចូលជាធរមានសិន ។ លោកនាយករដ្ឋមន្ត្រីក៏បានស្នើសុំឱ្យអាជ្ញាធរពាក់ព័ន្ធពិនិត្យឡើងវិញរាល់កិច្ចសន្យាដែលមានស្រាប់ ហើយបានបញ្ជាក់ថា ត្រូវធ្វើការបែងចែកដីធ្លីទៅឱ្យប្រជាពលរដ្ឋក្រីក្រដែលត្រូវការចាំបាច់សំរាប់ចិញ្ចឹមជីវិត ។ លោកតំណាងពិសេសសង្ឃឹមថា កំណែទម្រង់ទាំងនេះនឹងត្រូវបានអនុវត្តដោយគ្មានការពន្យាពេលឡើយ ។

៥៣. លោកតំណាងពិសេសបានសំដែងនូវសេចក្តីសោកស្តាយជាសាធារណៈ អំពីករណីនៃការគប់គ្រាប់បែក ដែលកើតមាននៅខាងចុងបេសកកម្មលើកទី១១ របស់លោក នាយប់ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៤ ទៅលើអ្នកស្រុកពីខេត្តពោធិសាត់ និងខេត្តកំពង់ឆ្នាំង ដែលធ្វើការតវ៉ាអំពីការបន្តសកម្មភាពនៅលើដីសម្បទានមួយកន្លែងដែលមានទំហំ ១៣៨.៩៦៣ ហិកតា ដែលបានផ្តល់សំរាប់ដាំដើមប្រេងខ្យល់ ក្នុងខែមករា ឆ្នាំ២០០០ ដល់ក្រុមហ៊ុនភាពីម៉ិច នៅក្នុងខេត្តពោធិសាត់ ។ លោកតំណាងពិសេសបានស្នើសុំឱ្យធ្វើការស៊ើបអង្កេត ហើយលោកបានអំពាវនាវឱ្យអាជ្ញាធរស្តាប់ប្រជាពលរដ្ឋ នឹងឆ្លើយតបទៅនឹងការព្រួយបារម្ភរបស់ពួកគេ ។ នៅក្នុងពេលធ្វើរបាយការណ៍នេះ មិនមាននរណាម្នាក់ត្រូវបានចាប់ខ្លួនដោយការវាយប្រហារ ដែលមានអ្នកស្រុកចំនួនប្រាំបីនាក់ត្រូវរងរបួស។ មិនតែប៉ុណ្ណោះ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីអនុវត្តច្បាប់បានធ្វើការយាយីជាច្រើនលើកច្រើនសារដល់តំណាងអ្នកស្រុករស់នៅក្នុងតំបន់ដីសម្បទាន ហើយអង្គការក្រៅរដ្ឋាភិបាលធ្វើការជាមួយសហគមន៍ទាំងនោះក៏បានទទួលការគំរាមកំហែងនេះដែរ ។

៥៤. លោកតំណាងពិសេសមានសេចក្តីព្រួយបារម្ភចំពោះស្ថានភាពមិនល្អ របស់ប្រជាពលរដ្ឋទូទៅនៅតំបន់ជនបទនៃប្រទេសកម្ពុជានឹងរឹតតែមានការលំបាកច្រើនថែមទៀតចំពោះការប្រើប្រាសដីធ្លី និងធនធានធម្មជាតិដែលប្រជាពលរដ្ឋពឹងផ្អែកសំរាប់ការប្រកបរបរចិញ្ចឹមជីវិត ។ លោកមានសេចក្តីព្រួយបារម្ភជាពិសេសចំពោះជំលោះលើដីធ្លី និងធនធានធម្មជាតិដែលបណ្តាលឱ្យមានអំពើហឹង្សា និងការយាយីទៅលើអ្នកស្រុក ដូចជានៅស្រុកស្នួល ក្នុងខេត្តក្រចេះ ដែលអ្នកស្រុកត្រូវបានគេគំរាមកំហែង និងការបៀតបៀនដល់រាងកាយ ពីសំណាក់ទាហាន ក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០០៤ និងក្នុងខេត្តបាត់ដំបងមានអ្នកស្រុកជាច្រើននាក់ត្រូវបានចាប់ខ្លួន និងចោទប្រកាន់តាមផ្លូវតុលាការ នៅចុងឆ្នាំ២០០៤ បន្ទាប់ពីចាប់ផ្តើមប្រមូលផលស្រូវ ដែលពួកគេបានដាំដុះនៅលើដីស្រែដែលពួកគេបានកាន់កាប់ ចាប់តាំងពីទសវត្សឆ្នាំ

១៩៨០ ដែលបានក្លាយជាកម្មវត្ថុនៃជំលោះ បន្ទាប់ពីមានទាហានជាច្រើននាក់ បានដណ្តើមកាន់កាប់ដីនោះនៅចុងទសវត្សឆ្នាំ១៩៩០ ហើយទាហានបានលក់ដីនោះទៅឱ្យម្ចាស់ដីថ្មីទៀត ។

៥៥. ដូចដែលលោកតំណាងពិសេសបានគូសបញ្ជាក់នៅក្នុងរបាយការណ៍របស់លោក ស្តីពីដីសម្បទានគោលដៅសេដ្ឋកិច្ច ក្រោយពីមានកំហុសនៅក្នុងទសវត្សកន្លងមក នៅមិនទាន់រកឃើញវិធីដោះស្រាយនៅឡើយ ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាល ប្រទេសអ្នកផ្តល់ជំនួយ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិកំពុងចាប់ផ្តើមចោទសួរអំពីគំរូនៃការអភិវឌ្ឍន៍សម្បទាន ហើយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់កំពុងខិតខំដោះស្រាយបញ្ហាមួយចំនួន ដោយមានការជួយឧបត្ថម្ភពីប្រទេសអ្នកផ្តល់ជំនួយ តាមរយៈគំរោងគ្រប់គ្រង និងរដ្ឋបាលដីធ្លី ។ គំរោងបន្ថែមមួយដែលហៅថា " គំរោងបែងចែងដីធ្លីសំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច " ដែលនឹងត្រូវផ្តួចផ្តើមធ្វើនៅពេលដែលវិស័យសំខាន់ៗ ដទៃទៀតត្រូវបានកំណត់ ។ ការប្តេជ្ញាចិត្តត្រូវបានធ្វើឡើង ដើម្បីធានាឱ្យមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន ការវាយតំលៃអំពីហេតុប៉ះពាល់សង្គមកិច្ច និងបរិស្ថាន ការបើកឱ្យមានការដេញថ្លៃ ការធ្វើរបាយការណ៍ការងារការត្រួតពិនិត្យពីខាងក្រៅ និងការបង្កើតប្រាក់ចំណូលរដ្ឋ ។ ការប្តេជ្ញាចិត្តទាំងនេះ ត្រូវតែអនុវត្តតាម ។

៥៦. នៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់សំរាប់ប្រទេសកម្ពុជា កាលពី ខែធ្នូ កន្លងទៅនេះ មានការព្រមព្រៀងគ្នាលើវិធានការមួយចំនួនស្តីពីការធ្វើឱ្យប្រសើរឡើងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរស់នៅតំបន់ជនបទ ។ ការប្រកាសជាសាធារណៈឱ្យបានឆាប់រហ័សអំពីកិច្ចសន្យាសម្បទានដែលមានស្រាប់ទាំងអស់ និងស្ថានភាពនៃការអនុវត្តកិច្ចសន្យាគ្រប់គ្រងដីសម្បទានគោលដៅសេដ្ឋកិច្ច សម្បទានរ៉ែ និងឡូតិ៍នេសាទ និងការបន្តប្រកាសពីស្ថានភាពនៃការពិនិត្យលើសម្បទានព្រៃឈើគឺមានសារៈសំខាន់ជាពិសេស ក៏ដូចជាការប្រកាសអំពីទីតាំង ស្ថានភាពផ្លូវច្បាប់ និងកិច្ចដំណើរការក្នុងការបញ្ចប់សម្បទានរ៉ែ តំបន់អភិវឌ្ឍន៍យោធា ដីសម្បទានគោលដៅសេដ្ឋកិច្ច និងការរៀបចំផ្សេងៗទៀតសំរាប់ការអភិវឌ្ឍន៍នៅក្នុងដីព្រៃ ឬតំបន់ការពារ និងស្របតាមច្បាប់ស្តីពីការគ្រប់គ្រងតំបន់ទាំងនេះ ។

៥៧. លោកតំណាងពិសេសយល់ឃើញថា ប្រសិនជាមិនចាត់វិធានការជាបន្ទាន់ដើម្បីដោះស្រាយបញ្ហានៃការគ្រប់គ្រងរដ្ឋបាលដីធ្លី និងធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជាឱ្យបានល្អនោះទេ នឹងអាចកើតមានជំលោះច្រើនថែមទៀតចំពោះធនធានទាំងនេះ ហើយនៅទីបំផុតនឹងក្លាយទៅជាការគំរាមកំហែងដល់ស្ថេរភាពនយោបាយ ។

## ឆ. សិទ្ធិខាងលំនៅដ្ឋាន

៥៨.	ទោះជាមានការរីកចំរើនខ្លះនៅតំបន់មួយចំនួនក្នុងទីក្រុង ជាពិសេសនៅរាជធានីភ្នំពេញ លោកតំណាងពិសេសមានសេចក្តីព្រួយបារម្ភអំពីបញ្ហាជាច្រើន រួមមានជំលោះផ្សេងៗពាក់ព័ន្ធអ្នកអភិវឌ្ឍន៍ឯកជន ការបញ្ជាឱ្យជម្លៀសចេញដោយបង្ខំ  ដោយផ្អែកលើអធិបញ្ញាបណ្តោះអាសន្ន មុនពេលចេញសេចក្តីសំរេចពីតុលាការ និងផលប៉ះពាល់អវិជ្ជមាននៃការអភិវឌ្ឍន៍ឆាប់រហ័សនៃទីក្រុង ហេត្ថារចនាសម្ព័ន្ធនានាដូចជា ស្ពាន និងផ្លូវគមនាគមន៍ជាដើម ។ ទាំងនេះបង្ហាញឱ្យឃើញនូវការគំរាមកំហែងសំរាប់គ្រួសារក្រីក្រ ដែលប្រឈមនឹងគ្រោះថ្នាក់ដោយការបណ្តេញចេញដោយបង្ខំ ឬការតាំងទីលំនៅថ្មីដោយមិនមានការទូទាត់សំណងឱ្យបានត្រឹមត្រូវ និងយុត្តិធម៌ ។ នៅតំបន់ជនបទទេសចរណ៍ ការអភិវឌ្ឍន៍ផ្លូវគមនាគមន៍ ការសាងសង់ទំនប់ និងការផ្លាស់ទីលំនៅនៃប្រជាពលរដ្ឋរស់នៅតំបន់ទំនាបទៅកាន់តំបន់ដាច់ស្រយ៉ាល ធ្វើឱ្យប៉ះពាល់អវិជ្ជមានដល់សិទ្ធិខាងលំនៅស្ថានរបស់ប្រជាពលរដ្ឋរស់នៅជនបទ និងជនដែលងាយទទួលរងគ្រោះ ដូចជាជនជាតិដើមភាគតិច ។ ការរំលោភច្បាប់តែងកើតមានជារឿយៗ ហើយមិនមានកំណត់យន្តការនៃការទទួលខុសត្រូវបានល្អគ្រប់គ្រាន់ ។

៥៩.	លោកតំណាងពិសេសមិនយល់ស្របជាដាច់ខាតចំពោះការជម្លៀសដោយបង្ខំ និងដោយហឹង្សាទៅលើប្រជា-ពលរដ្ឋ ៤៦ គ្រួសារ កាលពីថ្ងៃទី៩ ខែមករា ឆ្នាំ២០០៤ និងប្រជាពលរដ្ឋ២៣៧ គ្រួសារ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០៤ ដែលបានធ្វើឡើងនៅរាជធានីភ្នំពេញ ។ លោកមានសេចក្តីព្រួយបារម្ភផងដែរអំពីការជម្លៀសដោយបង្ខំ និងដោយហឹង្សានៅទីក្រុងផ្សេងទៀត ដូចជានៅប៉ោយប៉ែត កាលពីចុងខែសីហា និងខែកញ្ញា ឆ្នាំ២០០៤ កន្លងទៅនេះ ។ លោកសូមស្វាគមន៍ចំពោះការបង្កើតឱ្យមាន កាលពីខែមករា ឆ្នាំ២០០៤ នូវក្រុមការងារ ពិសេសមួយខាងសិទ្ធិលំនៅស្ថាន ដោយក្រុមសិទ្ធិមនុស្ស និងក្រុមសិទ្ធិលំនៅស្ថាន ដើម្បីបង្ការការរំលោភសិទ្ធិខាងលំនៅស្ថាន និងការជម្លៀសដោយបង្ខំ ជាពិសេសនៅក្នុងរាជធានីភ្នំពេញ ។ លោកក៏សូមស្វាគមន៍ចំពោះ " សេចក្តីប្រកាសស្តីពីគោលការណ៍សំរាប់អនុវត្ត ដើម្បីឱ្យបានប្រសើរបំផុតក្នុងការអភិវឌ្ឍន៍លំនៅដ្ឋាន និងការគាំទ្រដល់ប្រជាពលរដ្ឋក្រីក្រ នៅក្នុងប្រទេសកម្ពុជា : ការលើកកំពស់ការអភិវឌ្ឍន៍ទីក្រុងដោយវិធីដោះស្រាយផ្អែកលើគោលការណ៍សិទ្ធិជាមូលដ្ឋាន " ដែលបានរៀបចំឡើងដោយក្រុមការងារពិសេសខាងសិទ្ធិលំនៅស្ថាន សហការជាមួយសាលាក្រុងភ្នំពេញ ។ លោកសង្ឃឹមថារដ្ឋាភិបាលនឹងគាំទ្រពេញទំហឹងដល់ការផ្តួចផ្តើមគំនិតនេះ ។

៦០.	នៅអំឡុងបេសកកម្មលើកទី១១ របស់លោក លោកតំណាងពិសេស រួមជាមួយអ្នកសំរបសំរួលប្រព័ន្ធសហប្រជាជាតិប្រចាំកម្ពុជា និងតំណាងសាលាក្រុងភ្នំពេញ បានទៅទស្សកិច្ចនៅអតីតរោងកុនហែមជាតិ ដែលមានប្រជាពលរដ្ឋច្រើនជាង ១០០ គ្រួសាររស់នៅដែលគេឱ្យឈ្មោះថា " សហគមន៍ហែមជាតិ " ។ ប្រជាពលរដ្ឋភាគច្រើនបានរស់

នៅក្នុងអាគារនោះអស់រយៈពេលជាង២០ ឆ្នាំមកហើយ ស្ថិតក្នុងស្ថានភាពអមនុស្សធម៌ និងដែលមិនអាចទទួលយកបាន ។ លោកតំណាងពិសេសសង្ឃឹមថា មន្ត្រីរដ្ឋាភិបាលនឹងរិះរកដំណោះស្រាយសមស្រប និងប្រកបដោយចីរភាពសំរាប់គ្រួសារទាំងនោះនៅពេលអានាគតដ៏ខ្លីខាងមុខ ដោយមានការជួយឧបត្ថម្ភពីប្រទេសអ្នកផ្តល់ជំនួយ និងទីភ្នាក់អភិវឌ្ឍន៍នានា ។

## ជ. អំពើពុករលួយ និងតម្លាភាព

៦១.	ការរីករាលដាលនៃអំពើពុករលួយស្ថិតនៅជាឧបសគ្គមួយសំរាប់ភាពជឿនលឿន នៅក្នុងការបង្កើតនីតិរដ្ឋ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច ហើយបញ្ហានេះត្រូវបានគូសបញ្ជាក់នៅក្នុងរបាយការណ៍ និងការស្ទង់មតិជាច្រើននាពេលថ្មីៗនេះ ។ បញ្ហាទាំងនេះ គឺជារូបភាពអាស្រូវនៃការប្រព្រឹត្តអំពើពុករលួយនៅគ្រប់ស្រទាប់ជាន់ថ្នាក់នៃសង្គម និងជាបរិធាននៃរដ្ឋដែលដឹកនាំដោយអំពើពុករលួយ គឺជាបញ្ហាមួយដែលបង្ហាញពីភាពមិនស្របគ្នាយ៉ាងខ្លាំងដោយអន្លើរវាងរបៀបវារៈឯកជននៃមន្ត្រីសាធារណៈ និងមុខងារសាធារណៈផ្លូវការរបស់ខ្លួន ហើយដែលអត្ថប្រយោជន៍ទទួលបានពីឱកាសសេដ្ឋកិច្ច និងអត្ថប្រយោជន៍ដែលរដ្ឋបានផ្តល់ឱ្យ ។ អំពើពុករលួយនាំឱ្យមានការបែងចែកធនធានសាធារណៈមិនស្មើគ្នាធ្វើឱ្យភាពមិនស្មើភាពគ្នាដែលមានស្រាប់រីតតែធ្ងន់ធ្ងរថែមទៀត ហើយធ្វើឱ្យអន្តរាយដល់ការគោរពសិទ្ធិមនុស្ស ។

៦២.	កាលពីខែកញ្ញាកន្លងទៅនេះ លោកនាយករដ្ឋមន្ត្រីបានប្រកាសសង្គ្រាម " ប្រឆាំងអំពើពុករលួយ "។ ដើម្បីគាស់រំលើងឫសគល់នៃអំពើពុករលួយបាន ទាមទារឱ្យមានការដោះស្រាយចំពោះការមិនទទួលខុសត្រូវ ដូចបានរៀបរាប់ខាងលើ និងការប្តេជ្ញាចិត្តអនុវត្តយុទ្ធសាស្ត្រពហុវិស័យឱ្យបានយ៉ាងទូលំទូលាយ ។

៦៣. មធ្យោបាយមួយដែលរដ្ឋាភិបាលអាចបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួននោះគឺ ការគោរពតាមការកំណត់ពេលអនុវត្ត ដែលបានព្រមព្រៀងនៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ ក្នុងខែមិថុនា ឆ្នាំ២០០៤ កន្លងទៅនេះ ។ ទីមួយ គឺការចោទប្រកាន់តាមផ្លូវតុលាការ ក្នុងករណីដែលបានរបាយការណ៍ថាមានអំពើពុករលួយ ដែលអាចធ្វើបានតាមច្បាប់ដែលមានស្រាប់ ។ ទោះជាដូច្នេះក្តី រយៈពេលពីរឆ្នាំកន្លះបានកន្លងផុតទៅ ចាប់តាំងពីមានការកំណត់ពេលអនុវត្តឆ្នាំ២០០២ មិនមានការចោទប្រកាន់តាមផ្លូវតុលាការចំពោះករណីអំពើពុករលួយ ឬការសូកប៉ាន់ ត្រូវបានផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌដែលមានស្រាប់ និងការអនុវត្តទោសនោះទេ ។ នេះរួមមាន២ករណីនៃការគៃបន្លំមូលនិធិ និងធនធានពីធានាគារពិភពលោក និងអង្គការកម្មវិធីស្បៀងអាហារពិភពលោក ។

៦៤.	ទីពីរ គឺការអនុម័តច្បាប់ដ៏រឹងមាំមួយប្រឆាំងអំពើពុករលួយ ដែលច្បាប់នេះបានដាក់ក្នុងរបៀបវារៈអស់រយៈពេលមួយទសវត្សមកហើយ ។ បច្ចុប្បន្ននេះ សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយស្ថិតនៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលច្បាប់នេះមិនមានលក្ខណៈគ្រប់គ្រាន់តាមការអនុវត្តដ៏ប្រសើរបំផុតជាអន្តរជាតិ តួយ៉ាងដូចជាអនុសញ្ញាអន្តរជាតិប្រឆាំងអំពើពុករលួយ ។ សេចក្តីព្រាងច្បាប់នេះទៀតសោតក៏ព្រាងមិនបានគ្រប់គ្រាន់ ហើយមានបញ្ហាជាច្រើនអំពីភាពរលូនផ្ទៃកខាងក្នុងនៃច្បាប់នេះថាជាអត្ថបទច្បាប់  ប្រមូលផ្តុំទៅដោយបញ្ហាជាច្រើនពាក់ព័ន្ធនឹងការអនុវត្ត និងការពង្រឹងអនុវត្តច្បាប់នៅក្នុងប្រទេសកម្ពុជា ។ លោកតំណាងពិសេសស្នើយ៉ាងទទូចសុំឱ្យរដ្ឋាភិបាលធ្វើការដោយមានការជួយឧបត្ថម្ភពីប្រទេសអ្នកផ្តល់ជំនួយ ធ្វើរៀបចំតាក់តែងច្បាប់នេះឡើងឱ្យបានស្របតាមបទដ្ឋានអន្តរជាតិ  ដោយមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋកម្ពុជា និងស្នើសុំឱ្យអនុម័តច្បាប់ និងប្រើប្រាស់ធនធានផ្សេងៗ សំរាប់ការអនុវត្តច្បាប់នេះ ។

៦៥.	សេចក្តីព្រាងច្បាប់នេះ បានស្នើបង្កើតគណៈកម្មាធិការប្រឆាំងអំពើពុករលួយ ។ តាមកំណត់ហេតុតាមដានរបស់ស្ថាប័នប្រហាក់ប្រហែលគ្នានេះនៅប្រទេសផ្សេងៗទៀត មិនមានប្រសិទ្ធិភាព ហើយទាមទារឱ្យមានលក្ខខណ្ឌជាច្រើនដើម្បីអនុវត្តឱ្យបានសំរេចសំរាប់ប្រទេសមួយដែលមានស្ថាប័នទន់ខ្សោយ ។ ប្រសិនបើគណៈកម្មាធិការនេះត្រូវបានបង្កើតឡើង គឺសមាជិកទាំងអស់ចាំបាច់ត្រូវតែមានសេចក្តីសុចរិតទៀតត្រង់ល្អ និងឯករាជ្យ ហើយមានថវិកាគ្រប់គ្រាន់ ។ គួរធ្វើការពិចារណាលើវិធីផ្សេងៗ ក្នុងការពង្រឹងឯករាជ្យភាព ក៏ដូចជាក្នុងការបង្កើតឱ្យមានគណៈកម្មការប្រឹក្សាយោបល់ដែលមានសមាសភាពសង្គមស៊ីវិល និងសមាជិកនៃស្ថាប័នសាធារណៈ ដែលនឹងធ្វើការពិនិត្យពិច័យលើការងាររបស់គណៈកម្មាធិការ និងដើម្បីបង្កើនជំនឿទុកចិត្តដល់សាធារណៈជន នៅក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ។

៦៦. ប្រទេសកម្ពុជាគួរសុំចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ ដែលបច្ចុប្បន្ននេះមានប្រទេសជាង១០០ ហើយបានចុះហត្ថលេខា ក្នុងនោះរួមមានសមាជិកនៃរដ្ឋជាច្រើននៃសមាគមប្រជាជាតិអាស៊ីអាគ្នេរ ដែលហៅកាត់ថា (ASEAN) ។ រដ្ឋជាសមាជិកទាំងនោះត្រូវជាប់កាតព្វកិច្ចអនុវត្តអនុសញ្ញានេះ ដើម្បីផ្តល់នូវទម្រង់ជាក់លាក់មួយចំនួននៃការជួយឧបត្ថម្ភគ្នាទៅវិញទៅមកខាងវិស័យច្បាប់ ដូចជាការប្រមូល និងបញ្ជូនភស្តុតាងផ្សេងៗ សំរាប់ប្រើប្រាស់ក្នុងតុលាការ និងក្នុងការធ្វើបត្យាប័នជនល្មើស ក៏ដូចជាក្នុងការចាត់វិធានការមួយចំនួន ដែលនឹងជួយដល់ការស្វែងរកការឃាត់ខ្លួន ការដកហូត និងការរឹបអូសទ្រព្យសម្បត្តិដែលបានមកពីអំពើពុករលួយ ។ បទប្បញ្ញត្តិដទៃទៀតនៃអនុសញ្ញានេះ មានសារសំខាន់ជាពិសេសក្នុងការប្រយុទ្ធប្រឆាំងនឹងការកើតមានអំពើពុករលួយ ដែលពាក់ព័ន្ធនឹងប្រាក់យ៉ាងច្រើនសម្បើប ។

៦៧.	អន្តរាគមន៍ផ្នែកច្បាប់គ្រាន់តែជាផ្នែកមួយនៃទិដ្ឋភាពទាំងមូល ។ អនុសញ្ញានេះអំពាវនាវដល់ប្រទេសទាំងអស់លើកស្ទួយយ៉ាងសកម្មឱ្យមានការចូលរួមពីអង្គការក្រៅរដ្ឋាភិបាល អង្គការនានាដែលធ្វើការជាមួយសហគមន៍ក៏ដូចជាផ្នែកដទៃទៀតនៃសង្គមស៊ីវិល និងដើម្បីលើកកំពស់ការយល់ដឹងជាសាធារណៈស្តីពីអំពើពុករលួយ និងវិធានការដើម្បីជំនះបញ្ហានេះ ។ ទិសដៅដ៏ទូលំទូលាយមួយក៏នឹងទាមទារឱ្យមានការអនុម័ត និងអនុវត្តសេរីភាពនៃច្បាប់ស្តីពីព័ត៌មានដើម្បីឱ្យមានតម្លាភាពថែមទៀត និងរដ្ឋាភិបាលដែលមានការទទួលខុសត្រូវ បទបញ្ជារបស់ស្ថាប័នហិរញ្ញវត្ថុ បទដ្ឋានគណនេយ្យ នីតិវិធីសំរាប់ការស្នើសុំជាផ្លូវការ ជាពិសេសនីតិវិធី និងកិច្ចសន្យាទិញសំភារៈជាសាធារណៈ និងអន្តរាគមន៍ដទៃទៀត ។

៦៨.	ដូចដែលលោកតំណាងពិសេសបានគូសបញ្ជាក់នៅក្នុងរបាយការណ៍លើកមុន ព័ត៌មានដែលគ្រប់គ្រងដោយអាជ្ញាធរសាធារណៈមិនអាចទទួលបានតាមរយៈយន្តការស្ថាប័នច្បាស់លាស់នោះទេ ហើយជាទំលាប់អនុវត្ត ព័ត៌មានទាំងនេះទទួលបានតាមរយៈទំនាក់ទំនងផ្ទាល់ជាបុគ្គល ។ មន្ត្រីសាធារណៈត្រូវមានភារកិច្ចបំរើ និងទទួលខុសត្រូវចំពោះសាធារណៈជន ។ ព័ត៌មានដែលគ្រប់គ្រងដោយអាជ្ញាធរសាធារណៈ មិនបានតម្រូវឱ្យរក្សាទុកសំរាប់ជាប្រយោជន៍របស់មន្ត្រី ឬអ្នកនយោបាយនោះទេ ប៉ុន្តែគឺសំរាប់សាធារណៈជនទូទៅ ។ ការទទួលព័ត៌មានមានសារសំខាន់ណាស់សំរាប់ប្រជាពលរដ្ឋទាំងអស់ ក្នុងការចូលរួមដ៏មានប្រសិទ្ធិភាពនៅក្នុងការបង្កើត និងអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល និងសំរាប់ការពិភាក្សាផ្លាស់ប្តូរព័ត៌មានជាសាធារណៈអំពីសកម្មភាពរបស់រដ្ឋាភិបាល ។ កិច្ចប្រជុំក្រុមពិគ្រោះយោបល់កាលពីខែធ្នូកន្លងទៅនេះ បានសំរេចលើកិច្ចព្រមព្រៀងមួយចំនួន ដោយដាក់បញ្ចូលនូវបញ្ជីផែនការសកម្មភាពដែលរដ្ឋាភិបាលបានប្តេជ្ញាចិត្តរក្សាឱ្យមានតម្លាភាពនៃព័ត៌មាន ដែលគ្រប់គ្រងដោយអាជ្ញាធរសាធារណៈអាចត្រូវបានធ្វើការវាស់ស្ទង់បាន ។

## ឈ. កាតព្វកិច្ចសន្ធិសញ្ញាអន្តរជាតិ

៦៩.	បញ្ហានេះមានសារសំខាន់បំផុត ដែលប្រទេសកម្ពុជាបំពេញកាតព្វកិច្ចរបស់ខ្លួន ក្រោមសន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាជាភាគីហត្ថលេខី ។ កិច្ចដំណើរការធ្វើរបាយការណ៍ និងការផ្តល់ជាអនុសាសន៍ដោយស្ថាប័នសន្ធិសញ្ញាគួរតែពិនិត្យឡើងវិញ ដើម្បីផ្តល់ការជួយឧបត្ថម្ភដ៏មានតំលៃក្នុងការដាក់បញ្ចូលបទប្បញ្ញត្តិនៃសន្ធិសញ្ញាទៅក្នុងច្បាប់ និងការអនុវត្តរបស់ប្រទេសកម្ពុជា ហើយដើម្បីជំនះរាល់ឧបសគ្គដែលរារាំងដល់ការអនុវត្តសន្ធិសញ្ញានេះ ។ ជាថ្មីម្តងទៀត លោកតំណាងពិសេសស្នើយ៉ាងទទូចសុំឱ្យរដ្ឋាភិបាលចូលរួមយ៉ាងពេញទំហឹងនៅក្នុងកិច្ចដំណើរទាំងនេះ ដើម្បីលើកស្ទួយឱ្យមានកិច្ចពិភាក្សាថ្នាក់ជាតិ ដើម្បីផ្សព្វផ្សាយ អនុវត្ត និងពិនិត្យមើលអនុសាសន៍របស់ស្ថាប័នសន្ធិ-សញ្ញានានា និងសេចក្តីសន្និដ្ឋានសរុបរបស់ខ្លួន ។ នៅក្នុងឆ្នាំ២០០៣ គណៈកម្មាធិការប្រឆាំងទារុណកម្មបានចេញសំណុំ

អនុសាសន៍ដែលបានរៀបចំឡើង ដើម្បីបញ្ចប់ទំលាប់នៃការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលធ្វើឡើងដោយមន្ត្រីអនុវត្តច្បាប់នៅស្ថានីយនគរបាល និងពន្ធនាគារនានា ។ រដ្ឋាភិបាលថ្មីគួរចាត់ទុកបញ្ហាទាំងនេះជាអាទិភាព ។

៧០. កន្លងមកប្រទេសកម្ពុជាបានដាក់ជូនរបាយការណ៍ដំបូងរបស់ខ្លួន ក្រោមអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៤ ។ លោកតំណាងពិសេសសង្ឃឹមថាគណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ នឹងពិចារណាអំពីអាទិភាពនៃការធ្វើរបាយការណ៍នេះ ហើយថាកិច្ចពិភាក្សាដែលបានបង្កើតឡើងនឹងជួយធ្វើឱ្យប្រសើរឡើងថែមទៀតដល់ស្ថានភាព និងសភាពការណ៍របស់ស្ត្រីកម្ពុជាដែលនៅបន្តប្រឈមមុខនឹងការរើសអើង និងការលំបាកក្នុងជីវិតរស់នៅប្រចាំថ្ងៃ ។

៧១. មួយឆ្នាំកន្លងទៅនេះ គេសង្កេតឃើញមានការរីកចំរើនតិចតួច ក្នុងការបញ្ចប់របាយការណ៍ដំបូង ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលដល់ពេលកំណត់តាំងពី១០ ឆ្នាំកន្លងទៅនេះ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៤។ លោកតំណាងពិសេសស្នើយ៉ាងទទូចសុំឱ្យរដ្ឋាភិបាលកំណត់ការធ្វើរបាយការណ៍នេះជាបញ្ហាអាទិភាពបំផុតហើយ ការមិនសូវរីកចំរើនដែលរដ្ឋាភិបាល និងទីភ្នាក់នានានៃប្រទេសអ្នកផ្តល់ជំនួយបានធ្វើនៅក្នុងទសវត្សកន្លងទៅនោះ គឺការកាត់បន្ថយភាពក្រីក្រ ។ របាយការណ៍តាមកាលកំណត់ ក្រោមសន្ធិសញ្ញាដទៃទៀតក៏បានហួសរយៈពេលកំណត់ដែរ ។

៧២. លោកតំណាងពិសេសសូមស្វាគមន៍ ការចុះហត្ថលេខារបស់ប្រទេសកម្ពុជាលើពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ហើយលោកស្នើសុំឱ្យរដ្ឋាភិបាលផ្តល់សច្ចាប័នលើពិធីសារនេះឱ្យបានឆាប់ ។

៧៣. លោកតំណាងពិសេសបានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈមួយកាលពីខែឧសភា ឆ្នាំ២០០៤ ដែលបានស្នើយ៉ាងទទូចសុំឱ្យរដ្ឋាភិបាលគោរពតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ក្រោមអនុសញ្ញាឆ្នាំ១៩៥១ ស្តីពីឋានៈនៃជនភៀសខ្លួន និងពិធីសារ ឆ្នាំ១៩៦៧ នៃអនុសញ្ញានេះ ។ លោកមានសេចក្តីព្រួយបារម្ភជាពិសេសអំពីរបាយការណ៍ដែលថាមានមន្ត្រីអនុវត្តច្បាប់ និងកំលាំងសន្តិសុខបានជាប់ពាក់ព័ន្ធនៅក្នុងការរំលោភយ៉ាងធ្ងន់ធ្ងរ លើកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជាក្រោមអនុសញ្ញានេះ រួមមានការនិរទេសអ្នកស្វែងរកសិទ្ធិជ្រកកោនដោយបង្ខំ មកពីតំបន់ខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាម ដែលជនទាំងអស់នោះត្រូវគេស្គាល់ថាជាអ្នកភ្នំ ។

៧៤. បច្ចុប្បន្ននេះ សភាពការណ៍នៅក្នុងប្រទេសកម្ពុជាហាក់ដូចជាមានពន្លឺព្រាលៗហើយសំរាប់ការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សជាតិជាស្ថាប័នមួយដែលឯករាជ្យពិតប្រាកដ និងស្របតាមគោលការណ៍នៃសន្ធិសញ្ញាទីក្រុងប៉ារីស ។ រដ្ឋាភិបាល

ត្រូវកំណត់យកកិច្ចដំណើរការធ្វើរបាយការណ៍សន្ធិសញ្ញា និងការពង្រឹងស្ថាប័នជាតិដែលមានស្រាប់ ជាពិសេសស្ថាប័នតុលាការជាបញ្ហាអាទិភាពទី១ ។

## III. សេចក្ដីសន្និដ្ឋាន

៧៥. ប្រជាពលរដ្ឋកម្ពុជាបានឆ្លងកាត់ការឈឺចាប់ខ្លោចផ្សាររយៈពេលជាយូរណាស់មកហើយ ។ គោលដៅដ៏ចម្បងរបស់រដ្ឋាភិបាល និងសហគមន៍អន្តរជាតិ គឺជួយព្យាបាលរបួសនិងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ ចាប់តាំងពីខាងដើមនៃអាណត្តិរបស់លោក លោកតំណាងពិសេសតែងមានបំណងប្រាថ្នារួមចំណែក ដើម្បីសំរេចគោលដៅទាំងនេះ ។

៧៦. ប្រការដែលគួរឱ្យសោកស្ដាយនោះគឺ សង្គមកម្ពុជានៅតែទទួលរងការឈឺចាប់ដោយបច្ច័យអាក្រក់៤ ធំៗ ដែលលោកតំណាងពិសេសបានសំគាល់ឃើញនៅខាងដើមនៃអាណត្តិរបស់លោក ក្នុងនោះមាន ភាពក្រីក្រ អំពើហឹង្សា អំពើពុករលួយ និងការមិនគោរពច្បាប់ ។ នៅពេលនោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានយល់ស្របចំពោះការវិភាគនេះដែរ ។ លោកតំណាងពិសេសកត់សំគាល់ដោយសេចក្ដីសោកស្ដាយថា មិនត្រឹមតែរយៈពេលជាង៤ ឆ្នាំនៃអាណត្តិរបស់លោកប៉ុណ្ណោះទេ ប៉ុន្តែសូម្បីតែរយៈពេលជាង១០ ឆ្នាំនៃការចូលរួមយ៉ាងខ្លាំងខ្លាពីសហគមន៍អន្តរជាតិក៏ប្រទេសកម្ពុជាមិនបានធ្វើឱ្យមានការរីកចំរើនជាដំកំភួនក្នុងការជំនះនូវបច្ច័យអាក្រក់ទាំងបួននេះដែរ ជាពិសេស ភាពក្រីក្រនៅក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាភាគច្រើននៅមិនទាន់បានកាត់បន្ថយនៅឡើយ ។ លោកសម្ដែងនូវសេចក្ដីសោកស្ដាយ ដោយហេតុថាប្រទេសកម្ពុជាមិនមានភាពជឿនលឿនទៅមុខលើមាគ៌ាមួយឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យពហុបក្ស នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស ។ អ្វីដែលយើងបានឃើញបច្ចុប្បន្ននេះ ហាក់មិនបង្ហាញពីភាពជឿនលឿនទៅកាន់ទិសដៅទាំងនេះទេ ផ្ទុយទៅវិញវាមានភាពជឿនលឿនទៅរករូបភាពជារដ្ឋាភិបាលអត្តធិបតេយ្យ និងការប្រមូលផ្ដុំអំណាចខ្លាំងឡើងថែមទៀតនៅក្នុងដៃរបស់នាយករដ្ឋមន្ត្រី ។

៧៧. អាជ្ញាធរកម្ពុជា និងសង្គមស៊ីវិលក៏ដូចជាសហគមន៍អន្តរជាតិ និងប្រទេសអ្នកផ្ដល់ជំនួយនានាគួរធ្វើការវិភាគឱ្យបានហ្មត់ចត់អំពីការរីកចំរើន ចាប់តាំងពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងមូលហេតុដែលនាំឱ្យសំរេចជោគជ័យ និងការបរាជ័យ ។ ការវិភាគនេះមានសារៈសំខាន់ជាមូលដ្ឋានសំរាប់ជាមេរៀនដែលជាបទពិសោធក្នុងអតីតកាល សំរាប់ការអនុវត្តឱ្យបានសំរេចជោគជ័យនៅថ្ងៃអានាគត ។ មានហេតុផលជាច្រើនដែលអាចជឿបានថា ការវិភាគនេះនឹងបង្ហាញពីរចនាសម្ព័ន្ធអំណាចដែលពុករលួយ និងគ្មានតម្លាភាព គ្មានភាពស្មើគ្នាចំពោះមុខច្បាប់ នីទណ្ឌភាព ការឃុបឃិត និងការខ្វះតម្លាភាព និងការទទួលខុសត្រូវ ដែលជាឧបសគ្គមួយក្នុងចំណោមឧបសគ្គដទៃទៀតលើមាគ៌ាឆ្ពោះមួយទៅកាន់លទ្ធិប្រជាធិបតេយ្យពិតប្រាកដ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស សិទ្ធិមនុស្សទាំងអស់នៃប្រជាជាពលរដ្ឋកម្ពុជា ។ ឧបសគ្គទាំងអស់នេះត្រូវតែពិនិត្យដោះស្រាយ និងជំនះខាងតែបាន បើពុំនោះទេការរំដោះខ្លួនចេញពីការភ័យខ្លាច និងភាពទ័លក្រ ដូចបាន

ប្រកាសនៅក្នុងបុព្វកថានៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធមនុស្សនឹងបន្តស្ថិតនៅជាការសន្យាហើយមិនបានគោរពតាមសំរាប់ប្រជាពលរដ្ឋនៃប្រទេសកម្ពុជាទាំងមូល ។

## អនុសាសន៍

៧៨. លោកតំណាងពិសេសបានធ្វើអនុសាន៍ដ៏ទូលំទូលាយ និងពិស្តារនៅក្នុងរបាយការណ៍របស់លោកដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្ស និងមហាសន្និបាត អ.ស.ប ក្នុងនោះមានករណីជាច្រើនដែលលោកយល់ថាចាំបាច់ត្រូវលើកមកបញ្ជាក់ម្តងទៀត ដោយបញ្ហាជាច្រើនដែលបានលើកឡើងកន្លងមក មិនទាន់ត្រូវបានដោះស្រាយនៅឡើយ ។ អនុសាសន៍មួយចំនួនខាងក្រោមនេះ ឆ្លើយតបទៅនឹងកង្វល់ទាំងឡាយដែលបានលើកឡើង នៅក្នុងអំឡុងបេសកកម្មលើកទី១១ របស់លោក ។

### ក. ស្ថាប័នប្រជាធិបតេយ្យ

៧៩. ក្រុមប្រឹក្សាឃុំ សង្កាត់គួរត្រូវបានអនុញ្ញាតឱ្យធ្វើការជ្រើសរើសប្រធានភូមិ ដូចមានចែងក្នុងមាត្រា៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រសួងមហាផ្ទៃគួរចេញសេចក្តីណែនាំមួយដូចដែលបានតម្រូវស្តីពីទម្រង់បែបបទ និងនីតិវិធីសំរាប់ជ្រើសរើសប្រធានភូមិ ។

៨០. បញ្ញត្តិមួយនៃរដ្ឋធម្មនុញ្ញបានចែងអំពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលបញ្ញត្តិនេះគួរតែគោរពតាម ។

៨១. រដ្ឋសភាគួរធានាថា តំណាងរាស្ត្រនៃគណៈបក្សប្រឆាំង ត្រូវបានផ្តល់អាសនៈនៅក្នុងគណៈកម្មការទាំងប្រាំបួនរបស់រដ្ឋសភា ។

### ខ. ការរំលោភសិទ្ធិមនុស្សជាប្រព័ន្ធ និងនីទណ្ឌភាព

៨២. រដ្ឋាភិបាលត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីធានាថារាល់អំពើរំលោភសិទ្ធិមនុស្សនៅក្នុងអតីតកាល និងបច្ចុប្បន្នត្រូវបានធ្វើការស៊ើបអង្កេតទាំងស្រុង និងដោយមិនមានការជ្រៀតជ្រែកណាមួយដែលមិនសមហេតុផល ហើយថាជនទាំងឡាយ ដែលទទួលខុសត្រូវចំពោះអំពើរំលោភទាំងនេះ ត្រូវបញ្ជូនទៅតុលាការដើម្បីជំនុំជំរះ ។

៨៣.	សហគមន៍អន្តរជាតិគួរជំរុញឱ្យមានការស៊ើបអង្កេតទាំងស្រុង មិនលំអៀង និងដែលអាចជឿទុកចិត្តបានក្នុងករណីនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងធ្វើការចោទប្រកាន់តាមផ្លូវតុលាការចំពោះជនទាំងឡាយដែលទទួលខុសត្រូវ ។ ឃាដករសំលាប់លោក ជា វិជ្ជា ប្រធានសហជីពកម្មករកាលពីខែមករា ឆ្នាំ២០០៤ គឺជាករណីដែលត្រូវយកចិត្តទុកដាក់ ។

៨៤.	អង្គការអន្តរជាតិ រដ្ឋាភិបាលនៃប្រទេសនានា និងទីភ្នាក់ងារនៃប្រទេសអ្នកផ្តល់ជំនួយគួរជំរុញ និងគាំទ្រដល់សកម្មភាពផ្សេងៗ ដែលលើកកំពស់ការយល់ដឹងអំពីចរិតលក្ខណៈ និងភាពជាក់លាក់នៃបញ្ហានីទណ្ឌភាព និងជួយជំរុញឱ្យមានការពិភាក្សាជាមួយរដ្ឋាភិបាលដើម្បីបញ្ចប់បញ្ហានេះ ។

៨៥.	អង្គការអន្តរជាតិ និងទីភ្នាក់នៃប្រទេសអ្នកផ្តល់ជំនួយទាំងអស់គួរគាំទ្រថែមទៀតយ៉ាងពេញទំហឹងដល់អង្គការក្នុងស្រុកដែលការពារសិទ្ធិមនុស្ស ដើម្បីឱ្យពួកគេមានលទ្ធភាពបំពេញតួនាទីភារកិច្ចរបស់ខ្លួន ស្របតាមសេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គម ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលបានទទួលស្គាល់ជាសាកល ។

៨៦.	គួរតែបង្កើតឱ្យមានក្រុមប្រឹក្សាសាកសួរឯករាជ្យមួយ ដែលមានសមាសភាពតំណាងនានាដែលទទួលខុសត្រូវមកពីគណៈបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងអង្គការខាងសាសនានានា ដើម្បីពិនិត្យលើរាល់សកម្មភាពអំពើហឹង្សាដោយហ្វូងមនុស្សថាតើហេតុអ្វីបានជាកើតមានការវាយប្រហារទាំងនេះ ហើយត្រូវធ្វើយ៉ាងណា ដើម្បីទប់ស្កាត់បញ្ហាទាំងនេះ និងដើម្បីពិនិត្យពិច័យលើការអនុវត្តរបស់នគរបាល និងការចោទប្រកាន់តាមផ្លូវតុលាការនៅក្នុងការវាយប្រហារទាំងនេះ ។ ស្ថាប័ននេះគួរមានអំណាចដាក់ចេញនូវវិធានការខាងព្រហ្មទណ្ឌ និងការដាក់វិន័យ ។

## គ. ផ្នែកយុត្តិធម៌ និងនីតិរដ្ឋ

៨៧.	រដ្ឋាភិបាលគួរចាត់វិធានការជាបន្ទាន់ ដើម្បីបញ្ចប់ការជ្រៀតជ្រែកពីសំណាក់ស្ថាប័ននីតិប្រតិបត្តិទៅក្នុងការងាររបស់តុលាការ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

៨៨.	ដើម្បីផ្តល់ការគាំទ្រដ៏មានប្រសិទ្ធិភាពដល់កំណែទម្រង់វិស័យយុត្តិធម៌ ទីភ្នាក់ងារនៃប្រទេសអ្នកផ្តល់ជំនួយត្រូវធ្វើការពិចារណាឱ្យបានល្អិតល្អន់ថែមទៀតចំពោះភាពស្មុគស្មាញខាងនយោបាយ ដែលក្នុងរយៈកាលកន្លងមកមានការធ្វើអន្តរាគមន៍ជាច្រើនទៅក្នុងវិស័យនេះ នាំឱ្យការងាររបស់តុលាការគ្មានប្រសិទ្ធិភាព ។

## ឃ. សេរីភាពជាមូលដ្ឋាន

៨៩. រដ្ឋាភិបាលគួរចាត់វិធានការជាបន្ទាន់ ដើម្បីធានាឱ្យមានការគោរពនៅទូទាំងប្រទេសកម្ពុជានូវសិទ្ធិទាំងឡាយដែលបានការពារដោយរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ ដូចជាសេរីភាពក្នុងសំដែងមតិ សិទ្ធិក្នុងការបង្កើតសមាគម សេរីភាពក្នុងការប្រជុំ និងសិទ្ធិធ្វើបាតុកម្មអហឹង្សាជាដើម ។

៩០. រហូតដល់ច្បាប់ស្តីពីបាតុកម្មត្រូវបានរៀបចំព្រាងឡើងវិញ ដើម្បីឱ្យស្របតាមកាតព្វកិច្ចសន្ធិសញ្ញារបស់ប្រទេសកម្ពុជា អាជ្ញាធរគ្រប់ជាន់ថ្នាក់គួរអនុវត្តច្បាប់នេះឱ្យបានស្របតាមសិទ្ធិទាំងឡាយដែលការពារដោយរដ្ឋធម្មនុញ្ញ និងមាត្រា ២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

៩១. រដ្ឋាភិបាលគួរធ្វើសេចក្តីណែនាំដល់អាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋានទាំងអស់ ឱ្យគោរពសេរីភាពក្នុងការដើរហើរ ហើយត្រូវបញ្ចប់ការអនុវត្តដែលតម្រូវឱ្យប្រជាពលរដ្ឋ និងក្រុមមនុស្សសុំការយល់ព្រមមុនពេលធ្វើដំណើរ ។

៩២. រដ្ឋាភិបាលគួរធានាថាមន្ត្រីអនុវត្តច្បាប់អាចបំបែកហ្វូងបាតុករ និងការប្រមូលផ្តុំដទៃទៀតបានក្នុងករណីចាំបាច់បំផុតតែប៉ុណ្ណោះ ។ ក្នុងករណីនេះ ការប្រើប្រាស់កំលាំងអាចធ្វើបានតែក្នុងមធ្យោបាយចុងក្រោយ ហើយជានិច្ចកាលត្រូវតែមានហេតុផលត្រឹមត្រូវ សមាមាត្រទៅនឹងការការគំរាមកំហែងដែលបានបង្ករឡើង និងកាត់បន្ថយជាអប្បបរមានូវការធ្វើឱ្យខូចខាត ឬធ្វើរបួសដល់មនុស្ស និងទ្រព្យសម្បត្តិ ។

## ង. ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ

៩៣. រដ្ឋាភិបាលត្រូវប្រកាសឱ្យបានទូលំទូលាយនូវព័ត៌មានទាក់ទងនឹងសម្បទានទាំងអស់ រួមមានកិច្ចសន្យា ផែនទី និងព័ត៌មានស្តីពីក្រុមហ៊ុនសម្បទាន និងម្ចាស់ភាគហ៊ុននានារបស់ខ្លួន ។

៩៤. រដ្ឋាភិបាលគួរធ្វើមោឃភាពកិច្ចសន្យាទាំងឡាយណាដែលសម្បទានិកបានរំលោភធ្ងន់ធ្ងរលើកិច្ចសន្យា ឬបំពានច្បាប់ ហើយត្រូវធានាថាកិច្ចសន្យាទាំងអស់ត្រូវតែស្របច្បាប់ជាដាច់ខាត ។

៩៥. ទម្រង់ផ្សេងៗ នៃការអភិវឌ្ឍន៍វិស័យកសិកម្មសំរាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋនៅជនបទគួរបន្តអនុវត្តតទៅទៀត។ ប្រព័ន្ធដីសម្បទានគោលដៅសេដ្ឋកិច្ចចាំបាច់ត្រូវធ្វើការពិចារណាឡើងវិញ ។

៩៦. អនុក្រឹត្យនៃច្បាប់ភូមិបាលឆ្នាំ២០០១ ស្តីពីការធ្វើចំណាត់ថ្នាក់ " ដីសាធារណៈរបស់រដ្ឋ " និង" ដីឯកជនរបស់រដ្ឋ " ត្រូវតែអនុម័តឱ្យបានឆាប់រហ័ស ហើយត្រូវធ្វើចំណាត់ថ្នាក់ដីទាំងនោះផង ។

៩៧. រដ្ឋាភិបាលគួរអនុម័តអនុក្រឹត្យស្តីពីនីតិវិធីសំរាប់ការផ្តល់ និងការកាត់បន្ថយដីសម្បទានគោលដៅសេដ្ឋកិច្ចឱ្យបានឆាប់រហ័ស ។ ការលើកលែងណាមួយចំពោះដីដែលមានទំហំ១០.០០០ ហិកតា ដូចមានចែងក្នុងច្បាប់ភូមិបាល គួរតែកំណត់ឱ្យបានត្រឹមតែសមល្មមបានហើយ ។

៩៨. កិច្ចដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់សហគមន៍ជនជាតិដើមភាគតិច ត្រូវតែធ្វើឱ្យបានចប់សព្វគ្រប់ មុននឹងផ្តល់សម្បទានថ្មីណាមួយ ។ ត្រូវអនុម័តឱ្យបានឆាប់រហ័សនូវអនុក្រឹត្យដែលនឹងសំរួលដល់កិច្ចដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ។ រដ្ឋាភិបាលគួរប្រកាសឱ្យយ៉ាងទៀងទាត់នូវប្រាក់ចំណូលដែលបានមកពីសម្បទាន ដោយរួមទាំងទិន្នន័យលំអិតផងដែរ ។

៩៩. សម្បទានិកទាំងអស់គួរធ្វើគំរោងគ្រប់គ្រងប្រកបដោយចិរភាព និងអនុវត្តកិច្ចដំណើរការវាយតំលៃពីហេតុប៉ះពាល់បរិស្ថានដោយខានមិនបាន ។ រដ្ឋាភិបាលគួរចាត់ទុកការវាយតំលៃពីហេតុប៉ះពាល់សង្គមកិច្ចជាការចាំបាច់ ។

១០០. គួរធ្វើការដកហូតអាវុធពីកងសន្តិសុខ និងសេនាជនរបស់ក្រុមហ៊ុននៅលើដីសម្បទាន និងចំការកៅស៊ូនានាដោយគោរពតាមបញ្ញាជាធរមាន ។

## ច. សិទ្ធិខាងលំនៅដ្ឋាន

១០១. រដ្ឋាភិបាលគួរបញ្ចប់រាល់ការម្លៀសប្រជាពលរដ្ឋដោយបង្ខំ ហើយត្រូវអនុម័ត និងអនុវត្ត " សេចក្តីប្រកាសស្តីពីគោលការណ៍សំរាប់អនុវត្ត ដើម្បីឱ្យបានប្រសើរបំផុតក្នុងការអភិវឌ្ឍន៍លំនៅដ្ឋាន និងការគាំទ្រដល់ប្រជាពលរដ្ឋក្រីក្រនៅប្រទេសក្នុងកម្ពុជា " ដែលបានបង្កើតឡើងដោយក្រុមការងារខាងសិទ្ធិលំនៅស្ថាន សហការជាមួយសាលាក្រុងភ្នំពេញ ។

## ឆ. អំពើពុករលួយ និងតម្លាភាព

១០២. រដ្ឋាភិបាលគួរធានាថារាល់ករណីដែលបានរាយការណ៍ថាមានអំពើពុករលួយ ត្រូវបានស៊ើបអង្កេតទាំងស្រុង និងចោទប្រកាន់តាមច្បាប់ជាធរមាន ។ គួរប្រមូលទិន្នន័យ ដើម្បីឱ្យអាចពិនិត្យមើលការរីកចំរើននេះបាន ។

១០៣. សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយគួរដាក់ឱ្យមានការពិគ្រោះយោបល់ជាសាធារណៈយ៉ាងពេញលេញ និងឱ្យបានស្របតាមបទប្បញ្ញត្តិនៃអនុសញ្ញារបស់សហប្រជាជាតិប្រឆាំងអំពើពុករលួយ ។ ប្រទេសកម្ពុជាគួរចាត់វិធានការជាបន្ទាន់ ដើម្បីចូលជាភាគីនៃអនុសញ្ញានេះ ។

១០៤. តាមរយៈកិច្ចដំណើរការពិគ្រោះយោបល់ រដ្ឋាភិបាលគួររៀបចំច្បាប់មួយស្តីសេរីភាពខាងពត៌មាន និងធានាដល់ការអនុម័ត និងការអនុវត្តច្បាប់នេះ ។

## ឈ. កាតព្វកិច្ចសន្ធិសញ្ញាអន្តរជាតិ

១០៥. រដ្ឋាភិបាលគួរធានាថាប្រទេសកម្ពុជាគោរពតាមកាតព្វកិច្ចរបស់ខ្លួន ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលខ្លួនគឺជាភាគីនៃអនុសញ្ញានេះ និងអនុវត្តតាមអនុសាសន៍នានា ដែលធ្វើឡើងដោយស្ថាប័នសន្ធិសញ្ញាអន្តរជាតិ ។

១០៦. ប្រទេសកម្ពុជាគួរផ្តល់សច្ចាប័នលើពិធីសារបន្ថែមទៅលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាបានចុះហត្ថលេខាកាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ។

១០៧. ប្រទេសកម្ពុជាគួរចូលជាភាគីនៃអនុសញ្ញាលេខ១៦៩ ស្តីពីសិទ្ធិជនជាតិដើមភាគតិច និងពួកកុលសម្ព័ន្ធ ឆ្នាំ១៩៨៩ ដែលជាលិខិតុបករណ៍នៃច្បាប់អន្តរជាតិមានលក្ខណៈទូលំទូលាយបំផុត ដែលការពារសិទ្ធិជនជាតិដើមភាគតិច និងពួកកុលសម្ព័ន្ធ ។

-----

End.